**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវរបស់អនីតិជន ក្នុងបទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ទូច ដាវីត**

លោក **សន សោភ័ណ្ឌនិលណារាជ្យ**

ណែនាំដោយ

លោក **រុន ពណ្ណារិទ្ធ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ជាបឋមពួកយើងជានិស្សិតឆ្នាំទី៤ ផ្នែកថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ ជំនាន់ទី២៣ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ២០១៩-២០២៣ បានខិតខំស្រាវជ្រាវក្នុងគោលបំណងដើម្បីយល់កាន់តែច្បាស់ឲ្យស៊ីជម្រៅនៃការសិក្សាក្រោមប្រធានបទៈ "**ការទទួលខុសត្រូវរបស់អនីតិជនក្នុងបទល្មើសព្រហ្មទណ្ឌ**" ។

## ពួកយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុកអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងលះបង់កម្លាំងកាយចិត្តចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនៗ ទាំងស្មារតី និងសម្ភារៈ ដើម្បីឲ្យកូនក្លាយជាកូនល្អ ។ បន្ថែមពីនេះលោកទាំងពីរបានខិតខំប្រឹងប្រែងជម្រុញឲ្យកូនបានសិក្សារៀនសូត្រ ចាប់យកនូវចំណេះដឹងពីលោកគ្រូ និងអ្នកគ្រូចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនៃឧត្តមសិក្សាសាលាដ៏ល្អមួយនេះ ។ កូនគ្មានអ្វីក្រៅអំពីការខិតខំក្រេបយកនូវចំណេះវិជ្ជាទាំងពួងពីសំណាក់លោកគ្រូ អ្នកគ្រូដែលបានលះបង់កម្លាំងកាយចិត្ត និងផ្តល់នូវពុទ្ធិដែលជាទ្រព្យមិនអាចកាត់ថ្លៃបាន សម្រាប់ជាបញ្ញាញាណក្នុងការកសាងស្ពានទៅថ្ងៃអនាគតឲ្យបានថ្លៃថ្នូរ និងជាសសរទ្រូងនៃខ្លួនឯង គ្រួសារ និងសង្គមជាតិ ។

ស្របជាមួយគ្នានេះផងដែរសូមអរគុណដល់សាស្ត្រាចារ្យទាំងអស់ ជាពិសេសលោកគ្រូ **រុន ពណ្ណារិទ្ធិ** ដែលជាលោកគ្រូបង្គោលក្នុងការដឹងនាំយើងខ្ញុំ និងបានផ្តល់ឱកាសក្នុងការសិក្សាឈ្វេងយល់បន្ថែម នៅក្នុងមេរៀននីតិព្រហ្មទណ្ឌ ដែលជាច្បាប់សារធាតុសម្រាប់ការអនុវត្តន៍ និងការចែករំលែកគ្នា ។ យ៉ាងណាមិញបើក្រឡេកទៅមើលការសិក្សាដោយផ្ទាល់វិញ គឺមានភាពសកម្មនៅក្នុងការចូលរួមជាចំណែកក្នុងគោលដៅតែមួយគឺជាការសហការ សាមគ្គីភាព ទាំងការសិក្សា និងមិត្តភាពយ៉ាងកក់ក្តៅចំពោះគ្នាទៅវិញទៅមក ដើម្បីភាពជោគជ័យនៅថ្ងៃអនាគត ។

សិស្សច្បង និងរាមច្បង ដែលបានចូលរួមបង្ហាត់បង្ហាញ ពីការសិក្សាដែលជាគន្លឹះដ៏សំខាន់ នៃវិធីការសិក្សាមួយនេះ ។ បន្ថែមពីការសិក្សា ថែមទាំងលះបង់ពេលវេលាយ៉ាងច្រើន ដើម្បីជួយបំភ្លឺផ្លូវជីវិត ទាំងជីវិតការសិក្សា និងជីវិតនៅក្នុងការរស់នៅក្នុងសង្គម ដែលឈានទៅរកអនាគតមួយដ៏ប្រសើរសម្រាប់ជាសសរទ្រូងនៃប្រទេសជាតិរបស់យើង ។

# អារម្ភកថា

នៅថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ នូវគ្រប់មុខវិជ្ជាទាំងអស់ តាមកម្មវិធីសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងការស្រាវជ្រាវបន្ថែមពាក់ព័ន្ធទៅនឹង ការទទួលខុសត្រូវរបស់អនីតិជនក្នុងបទល្មើសព្រហ្មទណ្ឌ ពួកយើងមានចំណាប់អារម្មណ៍ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌនេះជាខ្លាំង ហើយការសរសេរសារណាបញ្ចប់ការសិក្សានេះ ពួកយើងបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយស្ដីអំពី «ការទទួលខុសត្រូវរបស់អនីតិជនក្នុងបទល្មើសព្រហ្មទណ្ឌ» បើយោងទៅការសិក្សាកន្លងមក និងសាស្ត្រាចារ្យដែលបានចូលរួមផ្ដល់ជាយោបល់ល្អៗ សម្រាប់ពួកយើង ដើម្បីឱ្យលេចចេញជារូបរាងឡើង ទុកជាឯកសារមួយដែលមានសារៈសំខាន់ និងអត្ថប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយៗ អាចយកទៅសិក្សារៀនសូត្រទៅអនាគត បើទោះបីជាមានគុណប្រយោជន៍តិចក្ដីច្រើនក្ដី ។

ពួកយើងសង្ឃឹមថាឯកសារមួយនេះពិតជាអាចផ្ដល់អត្ថប្រយោជន៍ទៅដល់អ្នកអាន និងសម្រាប់សិស្សប្អូនជំនាន់ក្រោយ ក្នុងការសិក្សាស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងប្រធានបទនេះ ។ ឯកសារមួយនេះមិនទាន់ល្អឥតខ្ចោះនៅឡើយនោះទេ អាចនឹងមានចំណុចខ្វះខាតមួយចំនួនដោយមិនបានធ្វើការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែពួកយើងសង្ឃឹមថាការស្រាវជ្រាវមួយនេះអាចរួមចំណែកមួយនៅក្នុងការសិក្សារបស់និស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់ពួកយើងរីករាយនឹងទទួលការរិះគល់ពីគ្រប់មជ្ឈដ្ឋាននានា ក្នុងគោលបំណងដើម្បីស្ថាបនា និងកែលម្អនូវរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយដោយក្ដីគោរពរាប់អាន ។

# មាតិកា

**សេចក្តីផ្តើម** ....... ១

## ជំពូកទី១

## លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

១.១. លក្ខខណ្ឌអាយុ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ....... ៤
១.១.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ....... ៥
១.១.២ អនីតិជនចាប់ពីអាយុ១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ....... ៦
១.២. កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ....... ៧
១.២.១ កាលៈទេសៈនៃបទល្មើស ....... ៨
១.២.២ បុគ្គលិកលក្ខណៈរបស់អនីតិជន ....... ១០

## ជំពូកទី២

## លំហូរនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់អនីតិជន

២.១ នីតិវិធីនៃការស៊ើបអង្កេត និងចោទប្រកាន់ដោយតំណាងអយ្យការ ....... ១២
២.១.១ ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ....... ១២
២.១.២ ការចោទប្រកាន់ដោយតំណាងអយ្យការ ....... ១៦
២.២ ដំណាក់កាលនៃការស៊ើបសួរ ....... ២២
២.២.១ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ....... ២២
២.២.២ ការស្តាប់ចម្លើយរបស់ចៅក្រមស៊ើបសួរ ....... ២២
២.២.៣ អំណាចចៅក្រមស៊ើបសួរក្នុងការបង្វែរ ....... ២៣
២.២.៤ ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ....... ២៣
២.២.៥ ការដោះលែងអនីតិជនឱ្យនៅក្រៅឃុំ ....... ២៤
២.២.៦ ការចេញនូវដីកាដំណោះស្រាយបិទការស៊ើបសួរ ....... ២៤
២.៣ ដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ ....... ២៥
២.៣.១ នីតិវិធីមុនពេលសវនាការ ....... ២៥
២.៣.២ នីតិវិធីសវនាការ ....... ២៦
២.៣.៣ ការប្រកាសសាលក្រម ....... ២៦

## ជំពូកទី៣
## វិធានការអនុវត្តទោសចំពោះអនីតិជន


៣.១ ទណ្ឌកម្មព្រហ្មទណ្ឌដែលអនុវត្តចំពោះអនីតិជន ........ ២៨
៣.២ ទោសដែលអាចអនុវត្តចំពោះអនីតិជន ........ ២៨
៣.២.១ មូលទោស ........ ២៨
៣.២.២ ការប្រកាសទោសបន្ថែម ........ ៣០
៣.២.៣ ការងារសហគមន៍ ........ ៣១
៣.២.៤ ស្ថានសម្រាលទោសចំពោះអនីតិជន ........ ៣១
៣.៣ ការអនុវត្តទោសចំពោះអនីតិជន ........ ៣២
៣.៣.១ ការពិន័យចំពោះអនីតិជន ........ ៣២
៣.៣.២ ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ........ ៣៤
**សេចក្តីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការសម្រេចឱ្យជនណាម្នាក់ឱ្យទទួលខុសត្រូវទៅលើទោសទណ្ឌព្រហ្មទណ្ឌគឺ ជារឿងមួយដែលគួរតែវែកញែក និងពិចារណាឱ្យបានដិតដល់បំផុត ប្រសិនបើមានការធ្វេសប្រហែសក្នុងការស្វែងរកភស្តុតាង ឬពិនិត្យពិច័យទៅលើអង្គហេតុណាមួយឲ្យបានស៊ីជម្រៅនោះទេ វាអាចនឹងបណ្តាលឱ្យជននោះរងនូវភាពអយុត្តិធម៌ជាមិនខាន ។ មួយវិញទៀតប្រសិនបើជនល្មើសនោះជាអនីតិជនវិញ គឺត្រូវតែមានការយកចិត្តទុកដាក់លើចំណុចនេះទ្វេដង ដូចជ្រាបហើយថាអនីតិជន គឺជាអ្នកបន្តវេនជំនាន់ក្រោយ ហើយប្រទេសមួយមានភាពរឹងមាំ និងរីកចម្រើនដោយសារតែអ្នកដឹកនាំមានការយកចិត្តទុកដាក់ខ្ពស់ទៅលើពួកគេ ព្រោះថាប្រសិនបើអនីតិជនទាំងនោះធ្លាក់ក្នុងផ្លូវមិនល្អ ពោលគឺការប្រព្រឹត្តបទល្មើសនោះវានឹងបង្កជាភាពអាណាធិបតេយ្យដល់សង្គម ឬបាត់បង់នៅសណ្តាប់ធ្នាប់សាធារណៈដែលនាំឲ្យសង្គមធ្លាក់ផ្លូវអន្តរាយជាមិនខាន ។

អនីតិជនត្រូវបានគេដឹងថា ជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត [1] ដូច្នេះប្រសិនបើអនីតិជននោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺគេតែងតែប្រើប្រាស់នូវវិធានការអប់រំ វិធានការតាមដាន វិធានការពារ និងវិធានការឧបត្ថម្ភ ជាជាងការដាក់ទោសទណ្ឌព្រហ្មទណ្ឌទៅលើពួកគេ តែប្រសិនបើបទល្មើសមានសភាពធ្ងន់ធ្ងរ ក៏ដូចជាមានសភាពឃោរឃៅ ឬមួយកាលៈទេសៈនៃជនល្មើសដែលជាអនីតិជននោះតម្រូវ ច្បាប់ក៏ត្រូវតែដាក់ទោសលើពួកគេដែរ តែស្ថិតក្នុងសភាពធូរស្រាលជាងនីតិជនទូទៅ ។ ការធ្វើបែបនេះមានគោលបំណងចង់ឱ្យអនីតិជនដែលប្រព្រឹត្តកំហុសទាំងនោះឱ្យដឹងពីកំហុសរបស់ខ្លួន កែប្រែខ្លួនឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ជៀសវាងការមិនដាក់ទោសពួកគេដែលនាំឱ្យពួកគេគិតថាច្បាប់បើកដៃឱ្យពួកគេប្រព្រឹត្តបទល្មើស ហើយប្រព្រឹត្តនូវកំហុសដដែលៗ ដែលបង្កឱ្យមានភាពចលាចលក្នុងសង្គម ។ អនុលោមតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ ហើយក្រមនេះពិតជាបានគិតគូរណាស់អំពីអនីតិជន ដូចយើងឃើញជាក់ស្តែងច្បាប់ព្រហ្មទណ្ឌយើង គឺបានជួយសម្រាលនូវទោសទណ្ឌរបស់ជនល្មើសដែលជាអនីតិជនដោយបង្វែរពីការដាក់ទោសពន្ធនាគារទៅជាវិធានការផ្សេងៗវិញ ដើម្បីមើលថែបណ្តុះបណ្តាលឱ្យពួកគេកែប្រែខ្លួន និងចូលទៅរួមរស់ក្នុងសង្គមវិញ ។

[1] ដកស្រង់ចេញពី «សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ» ដែលត្រូវបានរៀបចំឡើងដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយ

យ៉ាងណាមិញទោះបីជាច្បាប់កម្ពុជាយើងមានការបន្ធូរបន្ថយនូវទោសទណ្ឌកម្មចំពោះអនីតិជនក៏ដោយ អនីតិជននោះក៏មិនត្រូវប្រព្រឹត្តហួសនឹងព្រំដែនដែលច្បាប់បានកំណត់ដែរ ជាក់ស្តែងបើយើងពិនិត្យទៅមើលក្រមព្រហ្មទណ្ឌ អនីតិជនបានបែងចែកជាពីរ គឺអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ និងអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំ ។ វិធានការក្រៅពីទោសនេះ គឺច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺមិនអនុវត្តចំពោះជនល្មើសដែលជាអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំឡើយ ពោលគឺអនីតិជនស្ថិតក្នុងវ័យនេះទោះបីជាពួកគេប្រព្រឹត្តបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ពួកគេមិនត្រូវបានច្បាប់ដាក់ទោសដែរ ព្រោះគេយល់ថាអនីតិជនដែលស្ថិតក្នុងវ័យនេះគឺ មិនអាចបែងចែកបានឡើយថាតើអំពើណាដែលជាអំពើស្របច្បាប់ និងអំពើណាជាខុសច្បាប់ឡើយ ។ ក៏ប៉ុន្តែចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំវិញ គឺខុសពីអនីតិជនដូចបានរៀបរាប់ខាងលើ គឺច្បាប់អាចប្រកាសទោសពួកគេបានប្រសិនពិនិត្យទៅរកឃើញថា បទល្មើសមានចរិកលក្ខណៈគ្រោះថ្នាក់មិនអាចអត់ឱនឱ្យបាន ឬម៉្យាងទៀត គេអាចពិនិត្យទៅលើសភាពរបស់អនីតិជននេះផ្ទាល់ ដោយសំអាងថាអនីតិជននេះពិតជាអាចយល់ដឹងអំពីច្បាប់បានដែរឬទេ? តាមរយៈការធ្វើតេស្តទៅលើបញ្ញាស្មារតី កាយសម្បទា ក៏ដូចជាការស្ទង់នូវចិត្តគំនិតរបស់ពួកគេ ។ បើសិនជាគេយល់ថា អនីតិជនទាំងនេះមានលក្ខខណ្ឌសមស្របនោះច្បាប់នឹងប្រកាសទោសទៅលើពួកគេ ក៏ប៉ុន្តែទោសដែលអនុវត្តលើអនីតិជនទាំងនេះ គឺស្ថិតក្នុងស្ថានសម្រាល ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដោយពិនិត្យឃើញអំពីសារៈសំខាន់ក្នុងការសិក្សាលើប្រធានបទខាងលើ យើងខ្ញុំសូមលើកឡើងនូវចំណុចសំខាន់ៗដូចជា៖

- តើលក្ខខណ្ឌបែបណាដែលអនីតិជនត្រូវទទួលខុសត្រូវក្នុងបទល្មើសព្រហ្មទណ្ឌ ?
- ចំពោះអនីតិជនក្នុងបទល្មើសព្រហ្មទណ្ឌ តើនីតិវិធីដែលអនុវត្តត្រូវធ្វើឡើងយ៉ាងដូចម្តេច ?
- តើតុលាការនឹងអនុវត្តវិធានការបែបណាចំពោះអនីតិជនក្រោយពីប្រកាសទោស ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងផ្តល់ជាពុទ្ធិនិងអត្ថប្រយោជន៍ជាច្រើនដល់អ្នកសិក្សាស្រាវជ្រាវក៏ដូចជាអ្នកស្រលាញ់ខាងវិស័យច្បាប់ ហើយពិសេសជាងនេះទៅទៀត អត្ថបទស្រាវជ្រាវនេះ នឹងត្រូវបានយក

ទៅប្រើប្រាស់ទុកជាការស្វែងយល់នូវសញ្ញាណ និងគោលការណ៍សម្រាប់អ្នកច្បាប់ ឱ្យទទួលបាននូវចំណេះដឹងទាំងផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែង ជាពិសេសក្នុងរឿងក្តីព្រហ្មទណ្ឌដែលមានជនល្មើសជាអនីតិជន ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីសម្រួលដល់អ្នកអានក្នុងការទទួលជ្រាបនូវប្រធានបទនេះក្នុងគោលគំនិតត្រឹមដែនកំណត់ស្រាវជ្រាវក្នុងបរិបទសង្គមកម្ពុជានាពេលបច្ចុប្បន្ន វិសាលភាពនៃការស្រាវជ្រាវ គឺត្រូវបានកំណត់តែក្នុងបរិបទបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ហើយជាពិសេសនោះគឺ មានការពង្រីក និងពង្រឹងការយល់ដឹងលើប្រធានបទនេះ ដោយលើកយកបន្ថែមនូវលិខិតបទដ្ឋានគតិយុត្ត និងកម្រងអត្ថបទពាក់ព័ន្ធ ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

អត្ថបទស្រាវជ្រាវនេះត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពណ៌នា និងវិភាគ ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយបានប្រមូលព័ត៌មាន ក៏ដូចជាទិន្នន័យពាក់ព័ន្ធ ដូចជា រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់ពាក់ព័ន្ធមួយចំនួន ដែលធ្វើឱ្យការស្រាវជ្រាវប្រកបដោយសុក្រិដ្ឋភាពស្របតាមគោលការណ៍ច្បាប់កម្ពុជា ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សមិទ្ធផលដែលទទួលបានពីការស្រាវនេះនឹងក្លាយទៅឯកសារជំនួយស្មារតី ទៅដល់អ្នកសិក្សា អ្នកអាន និងអ្នកស្រាវជ្រាវ ។ កិច្ចការស្រាវជ្រាវនេះគឺជាផ្នែកមួយដែលជួយពន្លិចនូវគំនិតមួយចំនួនដែលជាគន្លឹះក្នុងការសិក្សាឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ ក៏ដូចជាធ្វើឱ្យអ្នកអានចេះបកស្រាយនូវសិទ្ធិ និងបង្ការការរំលោភអំណាចដោយអ្នកមានសមត្ថកិច្ចទៅលើអនីតិជនផងដែរ ។

## ៧. រចនាសម្ព័ន្ធ

ដើម្បីឱ្យការពន្យល់អត្ថបទកិច្ចការស្រាវជ្រាវនេះឱ្យកាន់តែមានភាពច្បាស់លាស់ និងកាន់តែស៊ីជម្រៅ យើងនឹងធ្វើការសិក្សាទៅលើរចនាសម្ព័ន្ធនៃប្រធានបទនេះ ដោយផ្តោតទៅលើ ៣ ជំពូកធំៗ ដូចជា ៖

**ជំពូកទី ១ លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

**ជំពូកទី២ លំហូរនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់អនីតិជន**

**ជំពូកទី៣ វិធានការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១

# លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

នៅក្នុងច្បាប់ព្រហ្មទណ្ឌជាគោលការណ៍ទូទៅ នៅពេលដែលមានបទល្មើសណាមួយកើតឡើង ទោះអំពើនោះប្រព្រឹត្តឡើងដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលជាហេតុបណ្តាលឱ្យមានព្យសនកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ដូច្នេះច្បាប់ព្រហ្មទណ្ឌ គឺជាបទដ្ឋានគតិយុត្តចែងកំណត់អំពីការដាក់ទណ្ឌកម្ម ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើដែលប៉ះពាល់ដល់ប្រយោជន៍បុគ្គល និងសណ្តាប់ធ្នាប់សាធារណៈ ។ ហេតុនេះបានជាក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាកម្រិតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ យោងតាមមាត្រា ៣៨ បានកំណត់ថា "**នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ**"[2] ដោយហេតុថាអាយុក្រោម ១៨ ឆ្នាំ គឺជាអនីតិជន ដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ ក៏ប៉ុន្តែនៅក្នុងមាត្រា ៣៩ កថាខណ្ឌទី២ បានបញ្ញត្តិបន្ថែមថា **តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបានដោយផ្អែកទៅលើលក្ខខណ្ឌអាយុ (១.១) ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ (១.២) ។**[3]

## ១.១. លក្ខខណ្ឌអាយុ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

យើងបានដឹងហើយថាច្បាប់បានកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ទើបមានការទទួលខុសត្រូវ ដោយហេតុថាអាយុក្រោម ១៨ឆ្នាំ គឺជាអនីតិជនដែលការយល់ដឹងរបស់ពួកគាត់នៅខ្វះខាតនៅឡើយ ប៉ុន្តែចំណុចនេះអាចមានភាពពិបាក ដោយហេតុថា ក្នុងករណីដែលមានអនីតិជនអាយុក្រោម ១៨ឆ្នាំ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរណាមួយ ។ ហេតុនេះហើយទើបក្នុងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិបន្ថែមទៀតថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបានប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ ។ មានន័យថាអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ ១៨ ឆ្នាំ អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌប្រសិនបើគេបានប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងច្បាប់ ហើយស្ថិតក្នុងលក្ខខណ្ឌសមស្របដែលតុលាកាអាចធ្វើការដាក់ទោសបាន ។

[2] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[3] មាត្រា ៣៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឲ្យបានច្បាស់លាស់ អំពីពាក្យថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនឡើយ ហេតុដូចនេះនៅពេលជួបប្រទះនូវករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការ (ឆន្ទានុសិទ្ធិ) ក្នុងការពិចារណាថា តើអនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏រួចផុតពីការទទួលខុសត្រូវចំពោះអំពើល្មើសរបស់ពួកគេ ។ ប៉ុន្តែតាមខ្លឹមសារនៃមាត្រា ៣៩ ដដែលមានន័យថា សម្រាប់អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនអាចត្រូវបានតុលាការព្រហ្មទណ្ឌប្រកាសឲ្យទទួលទោសបានឡើយ ។ ដូចនេះដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុខាងលើ យើងបានបែងចែកអនីតិជនជាពីប្រភេទ គឺ **អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ**( ១.១.១ ) និង**អនីតិជនចាប់ពីអាយុ១៤ឆ្នាំ ដល់ក្រោយ១៨ឆ្នាំ**( ១.១.២ ) ។

### ១.១.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ

ផ្អែកតាមអនុសញ្ញាស្តីពីសិទ្ធិកុមារមាត្រា ៤០ ត្រង់ចំណុចទី៣ កថាខណ្ឌ "ក"[4] បានកំណត់ថា រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថា ពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ ។ រីឯមាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងថា "**អនីតិជនមានអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់** ។[5] ចំណែកមាត្រា ២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន កថាខណ្ឌទី១ ក៏បានចែងផងដែរថា "**ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម**។[6] ហើយមាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន កថាខណ្ឌទី១ វាក្យខណ្ឌទី១ ដដែលនេះបានចែងថា "**អនីតិជនអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ**" ។[7]

ឧទាហរណ៍៖ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១៣ និង ៣០នាទី ជនរងគ្រោះឈ្មោះ **ក** ភេទស្រី អាយុ ៥៦ឆ្នាំ កំពុងអង្គុយនិយាយជាមួយបុគ្គលិកក្រុមហ៊ុនមួយ ដើម្បីស្នើសុំខ្ចីលុយនៅផ្ទះអ្នកជិតខាង ស្ថិតនៅសង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែជនសង្ស័យឈ្មោះ **ខ** ភេទប្រុស អាយុ

[4] មាត្រា ៤០ ត្រង់ចំណុចទី ៣ កថាខណ្ឌ "ក" ផ្អែកតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ

[5] មាត្រា ១៤ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[6] មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[7] មាត្រា ៣៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

០៨ឆ្នាំ(ត្រូវជាកូនប្រុសបង្កើតរបស់ជនរងគ្រោះ) បានយកចង្រ្កានហ្គាសចំនួន ០១ និងកំប៉ុងហ្គាសពីលើគ្រែខាងមុខផ្ទះដើរចូលទៅក្នុងបន្ទប់ រួចប្រមូលភួយ និងសម្ភារៈផ្សេងទៀតគរដាក់លើគ្រែពូក ហើយកាច់ចង្រ្កានហ្គាសបញ្ឆេះដុតបណ្តាលឱ្យឆេះខូចខាតទ្រព្យសម្បត្តិដូចជា៖ ១/គ្រែឈើ ចំនួន០១, ២/ពូកចំនួន០១, ៣/ភួយ រួចជនសង្ស័យក៏បានទៅដេកលើអង្រឹងក្រោមផ្ទះដូចធម្មតា ហើយកំប៉ុងហ្គាសក៏បានផ្ទុះឡើង ឮសូរសម្លេងដល់ជនរងគ្រោះ រួចជនរងគ្រោះក៏បានរត់មកមើលឃើញភ្លើងកំពុងឆេះចេញពីក្នុងបន្ទប់ដេករបស់ជនសង្ស័យ ទើបជនរងគ្រោះស្រែកឱ្យអ្នកជិតខាងជួយពន្លត់ភ្លើងរលត់វិញទៅ ។ ក្រោយពីធ្វើការសាកសួរជនសង្ស័យបានឆ្លើយសារភាពថា ខ្លួនពិតជាបានយកចង្រ្កានហ្គាសដុតផ្ទះ និងទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ដោយសារខឹងជនរងគ្រោះមិនព្រមទិញភេសជ្ជៈខាវ៉ាបាវឱ្យខ្លួនផឹក ។ ករណីករណីខាងលើនេះ ក្មេងដែលប្រព្រឹត្តអំពើនោះ មិនមានសតិស្មារតីគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនៅឡើយទេ ដោយហេតុថា ជនសង្ស័យដែលបង្កហេតុនេះ មានអាយុទើបតែ ៨ឆ្នាំ ហើយច្បាប់បានសន្មតមុនថា កុមារពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ ឬមិនទាន់មានការយល់ដឹងអំពើរបស់ខ្លួននៅឡើយ ដោយផ្អែកតាមអនុសញ្ញាស្តីពីសិទ្ធិកុមារមាត្រា ៤០ ត្រង់ចំណុចទី៣ កថាខណ្ឌ "ក" ។

**ចំណាំ៖** អាយុក្រោម ១៤ ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលរារាំងមិនឲ្យតុលាការធ្វើការប្រកាសទោសទៅលើអនីតិជននោះឡើយ ប៉ុន្តែមិនមែនមានន័យថា បានរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចនោះទេ (ការស្តីបន្ទោស ឬ វិធានការអប់រំ) ។ ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅ អនីតិជននោះឲ្យចូលខ្លួនមកកាន់តុលាការបានផងដែរ តែជានិច្ចកាលត្រូវតែមានអ្នកតំណាងដោយច្បាប់ (ឪពុកម្តាយ ឬអ្នកអាណាព្យាបាលទូទៅ) និងអាចជាមេធាវី ក្នុងគោលបំណងដើម្បីប្រកាសសេចក្តីសម្រេចដាក់ឲ្យអនុវត្តនូវវិធានការណាមួយ ដែលតុលាការបានធ្វើការសម្រេចលើអនីតិជននោះ ហើយប្រភេទនៃវិធានការរួមមាន វិធានតាមដាន វិធានអប់រំ វិធានការការពារ និងវិធានឧបត្ថម្ភ ឬប្រគល់អនីតិជននោះឲ្យទៅស្ថាប័នដែលដែលពាក់ព័ន្ធ ឬអាចដាក់អនីតិជននោះឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។ [8]

### ១.១.២ អនីតិជនចាប់ពីអាយុ១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ

ចំពោះអនីតិជនប្រភេទនេះវិញ នៅពេលដែលជននោះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ ។ ហេតុដែលច្បាប់តម្រូវឱ្យជននោះមានការទទួលខុសត្រូវ ដោយយល់ឃើញថា

[8] សារណារបស់និស្សិត ឈ្មោះ គា ភារ៉ា និងហេង វឌ្ឍនៈ ឆ្នាំ២០១៧ ទំព័រទី ៤

អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ ។ សមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងរាល់បញ្ហាដែលខ្លួនបានប្រព្រឹត្ត ។ ការយល់ឃើញបែបនេះ អាស្រ័យដោយហេតុថា នីតិករបានពិចារណាដោយផ្អែកទៅលើការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញាស្មារតី និងការសន្សំនូវរាល់បទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅកន្លងមករបស់អនីតិជននោះ ។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឱ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបាន គ្រប់គ្រាន់នូវការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចយល់ដឹងរាល់បញ្ហាដែលខ្លួនបានប្រព្រឹត្តថែមទៀតផង ។ ថ្វីត្បិតតែច្បាប់បានតម្រូវឱ្យអនីតិជនមានការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះ មិនមានលក្ខណៈពេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននោះត្រូវទទួលរង គឺមានកម្រិតស្រាលជាងនីតិជន ។ ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិនិត្យពិចារណាថ្លឹងថ្លែងជាមុនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់គាត់ផងដែរ ។[9] សូមបញ្ជាក់ផងដែរថា កម្រិតនៃទោស ត្រូវបន្ថយពាក់កណ្តាល បើប្រៀបធៀបទៅនឹងទោសដែលចែងសំរាប់នីតិជន ។

ឧទាហរណ៍ : ចំពោះបទឧក្រិដ្ឋមួយ ប្រសិនបើទោសដែលត្រូវទទួលរងមានជាប់ពន្ធនាគារ ២០ឆ្នាំ ទោសអតិបរមាមានតែ ១០ ឆ្នាំទេ ដែលអាចប្រកាសបានប្រឆាំងនឹងអនីតិជនដែលមានអាយុលើសពី ១៤ឆ្នាំ ។ នៅពេលដែលទោសដែលត្រូវទទួលរង គឺជាប់ពន្ធនាគារអស់មួយជីវិត ទោសអតិបរមាសំរាប់អនីតិជន គឺ ២០ឆ្នាំ ។ ដូចគ្នាដែរ ចំពោះអត្រាពិន័យ ដែលកម្រិតអតិបរមា និងអប្បបរមា ត្រូវបន្ថយពាក់កណ្តាល ។ ដូច្នេះ ក្រោមអាយុ ១៤ឆ្នាំ អនីតិភាព គឺប្រាកដជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ពីព្រោះគ្មានទោសណាមួយដែលអាចប្រកាសបានចំពោះអនីតិជនបានឡើយ ។ ផ្ទុយទៅវិញ ចាប់ពីអាយុ ១៤ឆ្នាំឡើងទៅ អនីតិភាព គឺជាមូលហេតុនៃការបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌវិញ ពីព្រោះថា ទោសទាំងឡាយដែលអាចសម្រេចប្រកាសបាន ចាំបាច់ត្រូវតែបន្ថយ ។

## ១.២. កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពុំបានចែងពីនិយមន័យ ឬលក្ខណៈវិនិច្ឆ័យនៃកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនឲ្យបានច្បាប់ឡើយ ។ ដូច្នេះដើម្បីអាចសម្រេចសេចក្តី

[9] នីតិព្រហ្មទណ្ឌទូទៅ, លោក កៅ សីហា ទំព័រ ២០៣

ប្រកបដោយសុក្រិត្យភាព និងសុភវិនិច្ឆ័យ ពោលគឺពឹងពាក់ទៅលើការពិចារណារបស់ចៅក្រមជំនុំជម្រះយ៉ាងមត់ម៉ាំ រួចចៅក្រមត្រូវតែធ្វើការត្រួតពិនិត្យឲ្យគ្រប់ជ្រុងជ្រោយទៅលើធាតុផ្សំសំខាន់ៗ ចំនួន ៣ គឺ **ទីមួយ** គឺគោលការណ៍នីត្យានុកូលដែលច្បាប់បានចែងពីទោសដែលអនីតិជនត្រូវទទួលខុសត្រូវ **ទីពីរ** គឺគោលការណ៍សត្យានុម័តនៃបទល្មើស ពោលគឺជាធាតុសំភារៈ ឬជាមធ្យោបាយអ្វីមួយ ហើយប្រព្រឹត្តនៅទីកន្លែងណា និង**ទីបី** គឺធាតុផ្សំអត្តនោម័ត ដែលយើងពិនិត្យទៅលើចេតនា ឬអចេតនា អាចនិយាយបានថាជាការមើលអំពីបុគ្គលិកលក្ខណៈនៃអនីតិជននោះផងដែរ ។

### ១.២.១ កាលៈទេសៈនៃបទល្មើស

កាលៈទេសៈនៃបទល្មើស គឺសំដៅទៅលើកត្តារួមផ្សំនៃបទល្មើសនេះឯង មានន័យថាកត្តាទាំងនេះគឺស្ថិតនៅក្នុងធាតុសត្យានុម័តនៃបទល្មើស ដែលកំណត់ពីបទល្មើស និងព្រំដែននៃបទល្មើស ហើយដោយផ្អែកទៅលើបទពិសោធន៍នៃសេចក្ដីសម្រេចរបស់តុលាការ ចៅក្រមត្រូវពិចារណាមើលទៅលើមធ្យោបាយប្រព្រឹត្តបទល្មើស វិធីសាស្ត្រនៃការប្រព្រឹត្តបទល្មើស ជាពិសេសគឺពេលវេលា ទីកន្លែង និងទិដ្ឋភាពនានា ។[10]

ឧទាហរណ៍ៈ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ២០នាទី មានជនរងគ្រោះឈ្មោះ **ក** ភេទប្រុស អាយុ ៤១ឆ្នាំ បានដើរទៅមើលផ្ទះរបស់បងប្អូន រួចហើយដើរត្រឡប់មកផ្ទះរបស់ខ្លួនវិញលុះមកដល់ចំណុចផ្លូវបេតុង ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ក៏ជួបនឹងជនសង្ស័យ១-ឈ្មោះ **ខ** ភេទប្រុស អាយុ ១៥ឆ្នាំ, ២-ឈ្មោះ **គ** ភេទប្រុស អាយុ ១៥ឆ្នាំ និង៣-ឈ្មោះ **ឃ** ភេទប្រុស អាយុ ១៦ឆ្នាំ បាននាំគ្នាឈរនៅតាមផ្លូវបេតុងខាងលើ ចំណែកឈ្មោះ **ខ** បានស្ទុះទៅចាប់ក្រៀកខ្លួនរបស់ជនរងគ្រោះជាប់ រួចហើយឈ្មោះ **គ** បានកាន់កាំបិតប៉ុងតោ ០១ដើម ចំណែកឈ្មោះ **ឃ** បានកាន់ដែកដំបងរលាស់ ០១ដើម ស្ទុះទៅកាប់ និងវាយទៅលើជនរងគ្រោះបណ្ដាលឱ្យជនរងគ្រោះរងរបួសដាច់រយៈលើកំភួនជើងខាងឆ្វេងដេរចំនួន១០ថ្នេរ និងស្នាមរលាត់ស្បែកលើផ្ទៃមុខ និងចេញឈាមនៅក្រោមខាងស្ដាំ ។ ពេលនោះក៏មានអ្នកជិតខាងចេញមកជួយ និងបានរាយការណ៍មកប្រាប់កម្លាំងសមត្ថកិច្ចនគរបាលឲ្យចុះមកជួយអន្តរាគមន៍នៅកន្លែងកើតហេតុ ដោយកម្លាំងសមត្ថកិច្ចនគរបាលបានចុះទៅអន្តរាគមន៍ និងបានឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ **ខ** ចំណែកជនសង្ស័យឈ្មោះ **គ** និងឈ្មោះ **ឃ** បានគេចខ្លួនបាត់ ហើយដកហូតវត្ថុតាងនាំយកមកប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី៣ រួចបញ្ជូនតាមនីតិវិធីតែម្តង ។

- មធ្យោបាយប្រព្រឹត្តបទល្មើស

[10] សារណារបស់និស្សិត ឈ្មោះ គា ភារ៉ា និងហេង វឌ្ឍនៈ ឆ្នាំ២០១៧ ទំព័រទី ៧

ផ្អែកទៅតាមអង្គហេតុខាងលើ មធ្យោបាយដែលយកមកប្រព្រឹត្តបទល្មើសនោះ រួចមានៈ កាំបិតប៉ុងតោ ០១ដើម, ដែកដំបងរលាស់ ០១ដើម ដែលជនល្មើសឈ្មោះ **គ** និងឈ្មោះ **ឃ** បានយកមកធ្វើសកម្មភាពនោះ ។ ដូចនេះមធ្យោបាយប្រព្រឹត្តបទល្មើស គឺសំដៅទៅការប្រើប្រាស់សម្ភារៈ ឧបករណ៍ ឬវត្ថុណាមួយដែលអនីតិជននោះបានយកទៅធ្វើសកម្មភាពដែលប្រាសចាកនឹងច្បាប់ ។

❖ វិធីសាស្ត្រប្រព្រឹត្តបទល្មើស

ផ្អែកទៅតាមអង្គហេតុខាងលើ វិធីសាស្ត្រប្រព្រឹត្តបទល្មើស គឺជនសង្ស័យឈ្មោះ **ខ** ភេទប្រុស អាយុ ១៥ឆ្នាំ, ២-ឈ្មោះ **គ** ភេទប្រុស អាយុ ១៥ឆ្នាំ និង៣-ឈ្មោះ **ឃ** ភេទប្រុស អាយុ ១៦ឆ្នាំ បាននាំគ្នាឈរនៅតាមផ្លូវបេតុងដើម្បីរង់ចាំជនរងគ្រោះត្រឡប់មកផ្ទះវិញ ចំណែកឈ្មោះ **ខ** បានស្ទុះទៅចាប់ក្រៀកខ្លួនរបស់ជនរងគ្រោះជាប់ រួចហើយឈ្មោះ **គ** បានកាន់កាំបិតប៉ុងតោ ០១ដើម ចំណែកឈ្មោះ **ឃ** បានកាន់ដែកដំបងរលាស់ ០១ដើម ស្ទុះទៅកាប់ និងវាយទៅលើជនរងគ្រោះបណ្តាលឱ្យជនរងគ្រោះរងរបួសដាច់រយះលើកំភួនជើងខាងឆ្វេងដេរចំនួន១០ថ្នេរ និងស្នាមរលាត់ស្បែកលើផ្ទៃមុខ និងចេញឈាម ។ ដូចនេះ វិធីសាស្ត្រប្រព្រឹត្តបទល្មើស សំដៅលើវិធីសាស្ត្រ បែបផែន ឬតិចនិចក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ តំណាងអយ្យការអាចនឹងធ្វើការចោទប្រកាន់អនីតិជននោះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់** ដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ ។ ប៉ុន្តែស្ថានទម្ងន់ទោសនេះ ចៅក្រមជំនុំជម្រះនឹងធ្វើការពិចារណាបន្ធូបន្ថយ ដោយផ្អែកទៅតាមច្បាប់ដែលអនុវត្តចំពោះអនីតិជន ។

❖ ពេលវេលាក្នុងការប្រព្រឹត្តបទល្មើស

ផ្អែកទៅតាមអង្គហេតុខាងលើ ពេលវេលាក្នុងការប្រព្រឹត្តបទល្មើស គឺស្ថិតនៅចំណុចផ្លូវបេតុង ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង ២០នាទី ។ ដូចនេះពេលវេលាប្រព្រឹត្តបទល្មើស អាចជាពេលមួយ ឬរយៈពេលមួយជាកំណត់ដែលអំពើល្មើសនឹងច្បាប់ព្រហ្មទណ្ឌ បានស្តែងចេញមកខាងក្រៅ ។ មានន័យថា នៅក្នុងច្បាប់ព្រហ្មទណ្ឌ ពេលវេលា ប្រព្រឹត្តបទល្មើសជាសញ្ញាមួយសំរាប់កំណត់នូវបទល្មើសនោះផ្ទាល់ ។

❖ ទីកន្លែងប្រព្រឹត្តបទល្មើស

ផ្អែកទៅតាមអង្គហេតុខាងលើទីកន្លែងប្រព្រឹត្តបទល្មើស ផ្លូវបេតុង ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ ដូច្នេះ ទីកន្លែងប្រព្រឹត្តបទល្មើស មានន័យថា ជារង្វង់ដែនដីមួយជា

កំណត់ ដែលនៅទីនោះបទ ល្មើសបានចាប់ផ្ដើមនិងបញ្ចប់ ឬនៅទីនោះបច្ច័យនៃអំពើល្មើសច្បាប់បាន កើតឡើង ។ មានន័យថា ទីកន្លែងអាចជាចំណុចណាមួយ ឬជាតំបន់ដែនដីណាមួយជាកំណត់ ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិថា វាជាទីកន្លែងមួយដែលសំរាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ ។

❖ ទិដ្ឋភាពនានាជុំវិញបទល្មើស

ផ្អែកទៅតាមអង្គហេតុ ទិដ្ឋភាពនានាជុំវិញបទល្មើស ជនសង្ស័យទាំងបីខាងលើ បាននាំគ្នាឈរនៅតាមផ្លូវបេតុងខាងលើ ដើម្បីធ្វើសកម្មភាពវាយទៅលើជនរងគ្រោះបណ្ដាលឱ្យជនរងគ្រោះរងរបួសដាច់រយះលើកំភួនជើងខាងឆ្វេងដេរចំនួន១០ថ្នេរ និងស្នាមរលាត់ស្បែកលើផ្ទៃមុខ និងចេញឈាមនៅក្រោមខាងស្ដាំ ។ ករណីនេះប្រសិនបើជនល្មើសជានីតិជន បទល្មើសដែលគេប្រព្រឹត្តនោះនឹងអនុវត្តទៅតាមច្បាប់ព្រហ្មទណ្ឌទូទៅ ហើយអាចនឹងត្រូវបន្ថែមនូវស្ថានទម្ងន់ទោស ដោយផ្អែកទៅលើកាលៈទេសៈ និងចិត្តសាស្ត្ររបស់ជននោះ ។ តែដោយហេតុថា ជនល្មើសទាំងបីនេះជាអនីតិជន គឺទោះបីជាមានចេតនា ធ្វើសកម្មភាពវាយទៅលើជនរងគ្រោះយ៉ាងណាក៏ដោយ ក៏ពួកគេជាជនដែលការពារដោយច្បាប់ ដូច្នេះទោសដែលអាចអនុវត្តចំពោះអនីតិជន ត្រូវតែអនុវត្តទៅតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ១.២.២ បុគ្គលិកលក្ខណៈរបស់អនីតិជន

យោងតាមមាត្រា ៦៤ ចំណុច "គ" នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានចែងថា" បុគ្គលិកលក្ខណៈអនីតិជនមានដូចជា អាយុ កម្រិត យល់ដឹង បញ្ញា និងអត្តចរិករបស់អនីតិជននោះ" មានន័យថា បុគ្គលិកលក្ខណៈរបស់អនីតិជន សំដៅទៅលើសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននោះផ្ទាល់តែម្ដង ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។ ដូច្នេះ ជាមូលដ្ឋានដល់តុលាការអាចវាយតម្លៃបានថា អនីតិជនអាចយល់ដឹងឬមិនអាចយល់ដឹង គឺវាយតម្លៃបានតាមរយៈ ២បែប រួមមាន៖ **របបវេជ្ជសាស្ត្រ** និង**របបធម្មជាតិ** ។ [11]

❖ របបវេជ្ជសាស្ត្រ

នៅក្នុងរបបវេជ្ជសាស្ត្រ គេត្រូវគិតពិចារណាទៅលើស្ថានភាពនៃជម្ងឺដែលនាំឲ្យជននោះមិនអាចយល់ដឹងបានដូចជាមនុស្សដែលស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំ ពោលគឺជាជនដែលមាន ជម្ងឺសរសៃប្រសាទជាប្រចាំ ឬខ្សោយសតិ សតិបញ្ញាពុំប្រក្រតី ឬជម្ងឺផ្សេងៗទៀត ដែលបណ្ដាលឲ្យមានភាពរីករវក្នុងសកម្មភាពនៃសរសៃប្រសាទនេះតែម្ដង ។

[11] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ ហ៊ី សោភា ទំព័រ ៨០ ដល់ ៨៣

ជម្ងឺសរសៃប្រសាទជាប្រចាំ (វិកលចរិត) អាចមានរូបភាពជាក់ស្តែងខុសៗគ្នា ដែលនាំមកនូវលទ្ធផលសភាពជម្ងឺជាប្រចាំ ឬយូរអង្វែង ។

សភាពវឹកវរក្នុងសតិបញ្ញា ជាបណ្តោះអាសន្នស្តែងឡើងភ្លាមៗក្នុងរយៈពេលខ្លី ធ្វើឲ្យមានការបាត់បង់នូវការយល់ដឹង ភ្លេចទាំងស្រុង ឬមួយផ្នែកនៃករណីដែលបានកើតឡើងក្នុងពេលវេលា ដែលជម្ងឺបានបញ្ចេញសកម្មភាព ។

ស្ថានភាពជម្ងឺផ្សេងៗ គឺជាប្រភេទជម្ងឺដែលពុំមែនកើតឡើងក្នុងប្រព័ន្ធសរសៃប្រសាទជាប្រចាំ ឬ ម្តងម្កាលឡើយ ប៉ុន្តែត្រូវបានចាត់ទុកថាជាស្ថានភាពជម្ងឺប្រហាក់ប្រហែលទៅនឹងស្ថានភាពជម្ងឺសរសៃប្រសាទ ដូចជា ករណីប្រើប្រាស់ថ្នាំញៀន ជាដើម ។

❖ របបតាមបែបធម្មជាតិ

ចំណែករបបបែបធម្មជាតិ គឺគេពិចារណាទៅលើផ្នែកសរីរាង្គដោយពិនិត្យទៅលើអាយុរបស់ជននោះ រួមទាំងចំណេះដឹងរបស់គាត់ផងដែរ ។ ការពិចារណានេះ គឺផ្អែកទៅលើការរីកចម្រើននៃផ្នែកសរីរាង្គ ដែលពាក់ព័ន្ធរួមមាន បញ្ហាសរសៃប្រសាទ និងរាងកាយរបស់គាត់នោះឯង ។ អាស្រ័យហេតុនេះ ទើបក្នុងច្បាប់បានសន្មតថា អាយុ ១៤ ឆ្នាំ គឺអាចមានសមត្ថភាពយល់ដឹងបានខ្លះៗហើយ ដោយសារតែស្ថានភាពនៃការរីកចម្រើនផ្នែកខាងរូបរាង្គកាយនៃមនុស្ស និងការទទួលនូវឥទ្ធិពលផ្នែកខាងធម្មជាតិ រួមមានដូចជា បញ្ហាដែលពាក់ព័ន្ធជាមួយនឹងអាកាសធាតុ សេដ្ឋកិច្ច និងសង្គមនេះឯង ។

ដូច្នេះហើយ ទើបនៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់ថា ប្រសិនបើជាអនីតិជនដែលមាន អាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ហើយបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ ចៅក្រមអាចប្រកាសផ្តន្ទាទោសទៅ លើអនីតិជននោះបាន ។

# ជំពូកទី២

# លំហូរនៃនីតិវិធីក្នុងរឿងក្ដីព្រហ្មទណ្ឌសម្រាប់អនីតិជន

ក្នុងក្រមព្រហ្មនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានចែងលម្អិតអំពីនីតិវិធីដែលអនុវត្តដោយឡែកសម្រាប់តែអនីតិជនឡើយ ។ ហេតុដូច្នេះ បានសេចក្ដីថានីតិវិធីក្នុងរឿងក្ដីព្រហ្មទណ្ឌ នីតិវិធីនៃការជម្រះក្ដីដែលអនុវត្តចំពោះនីតិជនក៏ត្រូវយកមកអនុវត្តចំពោះអនីតិជនផងដែរ ក៏ប៉ុន្តែស្ថិតក្នុងស្ថានភាពពិសេសមួយ ដែលផ្ដល់ជាប្រយោជន៍ដល់អនីតិជននោះ ។ នីតិវិធីទាំងអស់នោះត្រូវឆ្លងកាត់ទៅតាមដំណាក់កាលដូចជា **នីតិវិធីនៃការស៊ើបអង្កេត និងចោទប្រកាន់ដោយតំណាងអយ្យការ** (២.១) **ដំណាក់កាលនៃការស៊ើបសួរ** (២.២) និង**ដំណាក់កាលជំនុំជម្រះ** (២.៣) ដែលគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់ចំពោះអនីតិជន និងត្រូវយកមកអនុវត្តផងដែរចំពោះមាត្រាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៅក្នុងអំឡុងពេលអនុវត្តនីតិវិធី ។

## ២.១ នីតិវិធីនៃការស៊ើបអង្កេត និងចោទប្រកាន់ដោយតំណាងអយ្យការ

នៅគ្រប់រឿងក្ដីព្រហ្មទណ្ឌ ជាទូទៅគឺមានការចាប់ផ្ដើមឡើងដោយការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលគោលបំណងនៃការស៊ើបអង្កេតនេះគឺ ដើម្បីពិនិត្យទៅលើបទល្មើស កំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។[12] បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះបន្តទៅកាន់ព្រះរាជអាជ្ញា ដែលជាម្ចាស់នៃបណ្ដឹងអាជ្ញា ដើម្បីចាត់ការបន្តទៅតាមនីតិវិធី ។

### ២.១.១ ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺដើរតួយ៉ាងសំខាន់ក្នុងដំណាក់កាលដំបូងបង្អស់នៃរឿងក្ដីព្រហ្មទណ្ឌ ព្រោះថានៅពេលដែលអនីតិជនបានប្រព្រឹត្តនូវបទល្មើស មន្ត្រីនគរបាលយុត្តិធម៌នឹងចាប់ផ្ដើមបើកការសង្កេតលើបទល្មើសដែលបង្កឡើងដោយអនីតិជននោះ ។ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចក្នុងការឃាត់ខ្លួន ការចាប់ខ្លួន ឬឆែកឆេរខ្លួន អនីតិជនដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ដែលសកម្មភាពទាំងនេះគឺស្ថិតក្នុងលក្ខខណ្ឌមួយដោយគិតដល់ឧត្តមប្រយោជន៍អនីតិជនជាធំ ។ រាល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងក្រោមការដឹកនាំ និងសម្របសម្រួលដោយព្រះរាជអាជ្ញា[13] ។ បន្ថែមពីនេះ ក្នុងករណីអនីតិជនដែលមាន

[12] មាត្រា ១២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[13] មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទលហុ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែធ្វើការអប់រំ ណែនាំព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។ ក្នុងករណីដែលអនីតិជនបានសារភាពថាខ្លួនពិតជាបានប្រព្រឹត្តបទលហុនោះពិតមែន មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការសម្របសម្រួលវាងភាគីពាក់ព័ន្ធ ដើម្បីបញ្ចប់វិវាទ ។ តែផ្ទុយទៅវិញ ប្រសិនបើក្នុងករណីដែលអនីតិជននោះមានអាយុក្រោម ១៤ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើស គឺពុំត្រូវបានឃាត់ខ្លួនឡើយ បើទោះស្ថានភាពបទល្មើសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ បន្ថែមពីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ ។[14] ការស៊ើបអង្កេតដែលទាក់ទងរឿងក្តីដែលបង្កឡើងដោយអនីតិជន គឺខុសពីរឿងក្តីដែលបង្កឡើងពីនីតិជនទូទៅ ហេតុដូច្នេះហើយមន្ត្រីនគរបាលយុត្តិធម៌ដែលស៊ើបអង្កេតក្នុងរឿងនេះ គឺត្រូវតែជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញ និងធ្លាប់ទទួលបាននូវការបណ្តុះបណ្តាលពិសេសដែលពាក់ព័ន្ធច្បាប់ស្តីពីអនីតិជន ដើម្បីឱ្យការអនុវត្តនីតិវិធីនេះប្រព្រឹត្តទៅដោយប្រសិទ្ធិភាពខ្ពស់ចំពោះកុមារ ។

❖ **ការឃាត់ខ្លួន**

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់យ៉ាងច្បាស់ថាអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស គឺពុំអាចឃាត់ខ្លួនឡើយ ប៉ុន្តែចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ច្បាប់នេះពុំបានកំណត់ឡើយ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ គឺមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការឃាត់ខ្លួនពួកគេ ដោយមូលហេតុថាអនីតិជននោះនឹងរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ឬបង្ករអំពើសន្តិសុខផ្សេងទៀត ឬក្នុងគោលបំណងការពារអនីតិជននោះផ្ទាល់ ។ រាល់ការឃាត់ខ្លួនអនីតិជនត្រូវតែរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញា ។[15] បន្ទាប់ពីជូនដំណឹងទៅព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវជូនដំណឹងជាបន្ទាន់អំពីការឃាត់ខ្លួន ទៅអ្នកតំណាងរបស់អនីតិជននោះ ដូចមានកំណត់ក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនផងដែរ ។

នៅពេលឃាត់ខ្លួនអនីតិជន មន្ត្រីវនគរបាលយុត្តិធម៌ត្រូវដាក់អនីតិជនដែលឃាត់ខ្លួននោះឱ្យដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ហើយជាពិសេសទៅទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវធានាឱ្យបានថា អនីតិជនដែលត្រូវបានឃាត់ខ្លួននោះមិនត្រូវបានទទួលទណ្ឌកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យទង្វើរដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ឬអំពើអនុស្សធម៌ណាមួយផ្សេងទៀតឡើយ ព្រោះថាប្រសិនបើមិនគោរព

[14] មាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[15] មាត្រា ១៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទៅតាមលក្ខខណ្ឌទាំងនេះទេ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។[16] ចំពោះថិរវេលានៃការឃាត់ខ្លួនអនីតិជន គឺមានកំណត់យ៉ាងច្បាស់ក្នុងមាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយៈ

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេ ឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

មាត្រាដដែលក៏បានបន្ថែមទៀតថា ចំពោះការពន្យាពេលឃាត់ខ្លួននឹងមិនត្រូវយកមកអនុវត្តចំពោះអនីតិជនឡើយ ។

❖ **ការចាប់ខ្លួន**

បន្ទាប់ពីរកឃើញថាអនីតិជនបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចាប់ខ្លួនអនីតិជន និងរាយការណ៍ភ្លាមទៅកាន់ព្រះរាជអាជ្ញា ដើម្បីធ្វើការចាប់ខ្លួនអនីតិជននោះ ។ ការចាប់ខ្លួនអនីតិជន គឺមន្ត្រីនគរបាលយុត្តិធម៌អាចចាប់ខ្លួនបានចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ វិញ ការចាប់ខ្លួននោះនឹងប្រព្រឹត្តទៅបានក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។[17] អំឡុងពេលអនុវត្តនូវការចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជៀសវាងការធ្វើឱ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន ។[18]

[16] មាត្រា ២៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[17] មាត្រា ១៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[18] មាត្រា ១៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

❖ **ការផែកឆេរ**

ចំពោះការផែកឆេរលើអនីតិជនវិញ មន្ត្រីនគបាលយុត្តិធម៌អាចផែកឆេរទៅលើជនសង្ស័យដែលជាអនីតិជនដែលមានភេទដូចគ្នាប៉ុណ្ណោះ ក្នុងករណីគ្មានជម្រើស មន្ត្រីនគបាលយុត្តិធម៌នោះអាចចាត់តាំងបុគ្គលណាម្នាក់ដែលមានភេទដូចគ្នា ឱ្យផែកឆេរជំនួសតែត្រូវប្រាកដថា អ្នកផែកឆេរដែលចាត់តាំងនោះត្រូវតែជាបុគ្គលដែលមិនពាក់ព័ន្ធនឹងបទល្មើស ឬមានទំនាក់ទំនងជាមួយនឹងជនសង្ស័យដែលជាអនីតិជននោះឡើយ (លើកលែងតែក្នុងករណីមិនអាចជៀសវាងបាន) ។[19]

❖ **ការស្ដាប់ចម្លើយ**

ដោយអនុលោមទៅតាមមាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន មុនពេលចាប់ផ្តើមនូវការស្តាប់ចម្លើយ អនីតិជនទទួលបាននូវសិទ្ធិសន្ទនាជាលក្ខណៈឯកជន និងជាសំងាត់ជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រាប់ដល់អនីតិជននោះ អំពីសិទ្ធិមូលដ្ឋានពិសេសដល់អនីតិជន ជាពិសេសគឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី និងសិទ្ធិផ្សេងៗទៀតដូចដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។ លើសពីនេះទៅទៀត ការស្តាប់ចម្លើយត្រូវប្រព្រឹត្តទៅដោយមានវត្តមានមេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីដែលមានលក្ខណៈឯកជន និងជាការសម្ងាត់ ។ បន្ថែមពីនេះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចក៏មានសិទ្ធិក្នុងការផ្តល់ជំនួយដល់អនីតិជន និងចូលរួមស្តាប់ចម្លើយរបស់អនីតិជនបានផងដែរ ។

បន្ទាប់ពីបញ្ចប់នូវការស្តាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុនៃចម្លើយបាន ។ លើសពីនេះទៅទៀត អនីតិជនក៏អាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនោះបាន ។ បន្ថែមពីលើនេះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលវត្តមានក៏ត្រូវចុះហត្ថលេខា និងផ្តិតស្នាមម្រាមដៃលើកំណត់ហេតុផងដែរ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះត្រូវមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម មិនដូច្នោះទេនឹងនាំឲ្យមានការមោឃភាពនៃនីតិវិធី ។

[19] មាត្រា ១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

❖ **ការបញ្ជូនភស្តុតាងទៅកាន់ព្រះរាជអាជ្ញា**

រាល់សកម្មភាពទាំងអស់របស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវកត់ត្រាចូលទៅក្នុងកំណត់ហេតុដោយមន្ត្រីនគបាលយុត្តិធម៌ដែលដឹកនាំការស៊ើបអង្កេតនោះ ។ នៅក្រោយពេលបញ្ចប់នីតិវិធីស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។[20] ប្រសិនបើអនីតិជនដែលត្រូវបានឃាត់ខ្លួន ផុតកំណត់រយៈពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំសេចក្តីសម្រេចពីព្រះរាជអាជ្ញា ថាត្រូវបញ្ជូនអនីតិជននេះទៅព្រះរាជអាជ្ញា ឬត្រូវដោះលែង ។[21] ប្រសិនបើមិនត្រូវបានដោះលែង នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនខ្លួនអនីតិជននោះទៅឱ្យព្រះរាជអាជ្ញាក្នុងរយៈពេលដ៏ឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។[22] ក្នុងករណីមានការយឺតយ៉ាវអំឡុងពេលបញ្ជូនខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ ។[23]

### ២.១.២ ការចោទប្រកាន់ដោយតំណាងអយ្យការ

តំណាងអយ្យការ គឺជាម្ចាស់នៃបណ្តឹងអាជ្ញាដែលបំពេញតួនាទីក្នុងការការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ ។ ការចោទប្រកាន់នូវករណីទាំងឡាយ ដែលពាក់ព័ន្ធនឹងអនីតិជនត្រូវឱ្យតំណាងអយ្យការ ដែលទទួលបានការចាត់តាំងពិសេសឱ្យកាន់រឿងក្តីអនីតិជន ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឱ្យកាន់រឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលទាក់ទងហ្នឹងយុត្តិធម៌អនីតជន ។[24]

#### ២.១.២.១ ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

នៅពេលដែលបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌រួចហើយ តំណាងអយ្យការ ត្រូវត្រួតពិនិត្យសំណុំឯកសារ និងបណ្តឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុពិតប្រាកដរបស់អនីតិជនមុននឹងធ្វើការចោទប្រកាន់ ឬលើកលែងចោលការចោទប្រកាន់ក្នុងករណីដែលអនីតិជននោះមានអាយុតិចជាង ១៤ឆ្នាំ គិតត្រឹមពេលដែលប្រព្រឹត្តបទល្មើស ។ ហើយមូលដ្ឋានក្នុងការបញ្ជាក់អាយុរបស់ជនល្មើសដែលជាអនីតិជននោះអាចយោងទៅលើសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សៀវភៅគ្រួសារ ឬឯកសារផ្សេងទៀតដែលអាចកំណត់អំពីកំណើតរបស់ជននោះ ។[25] ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជននោះ ព្រះរាជអាជ្ញា

[20] មាត្រា ១០៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[21] មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ១០៤ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23] មាត្រា ១០៤ កថាខណ្ឌទី៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[24] មាត្រា ២៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[25] មាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។[26] ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋាន អំពីអាយុពិតប្រាកដរបស់អនីតិជនព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។[27]

### ២.១.២.២ ការស្តាប់ចម្លើយដោយតំណាងអយ្យការ

ចំពោះនីតិវិធីក្នុងការស្តាប់ចម្លើយរបស់ជនល្មើសដែលជាអនីតិជនក្នុងដំណាក់កាលអយ្យការ ក៏មិនមានលក្ខណៈខុសគ្នាពីនីតិវិធីក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ប៉ុន្មានដែរ ក្រោយពីផ្ទៀងផ្ទាត់នូវអាយុរបស់អនីតិជនហើយ តំណាងអយ្យការនឹងធ្វើការស្តាប់ចម្លើយលើជនល្មើសនោះ ដោយមុនពេលស្តាប់ចម្លើយព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពី(សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) ។[28] ការស្តាប់ចម្លើយត្រូវតែធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។[29] បន្ទាប់ពីស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីដែលអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបានក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឱ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន និងចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ[30] ។

### ២.១.២.៣ ការសម្រេចដោយតំណាងអយ្យការ

ដោយផ្អែកទៅលើការស្តាប់ចម្លើយ និងពិនិត្យនូវភស្តុតាងទាំងឡាយចប់សព្វគ្រប់ តំណាងអយ្យការនឹងធ្វើចំណាត់ការបន្តទៅតាមនីតិវិធីទៅលើជនល្មើសដែលជាអនីតិជននោះ ។

- **ក្នុងករណីដែលតំណាងអយ្យការសម្រេចថាចោទប្រកាន់**

ក្នុងករណីតំណាងអយ្យការសម្រេចថាចោទប្រកាន់ នោះតំណាងអយ្យការនឹងបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។[31] ក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ តំណាងអយ្យការនឹងចេញនូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺបញ្ជាឱ្យជនជាប់ចោទដែលជាអនីតិជន

---

[26] មាត្រា ២៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[27] មាត្រា ២៥ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[28] មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[29] មាត្រា ២៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[30] មាត្រា ២៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[31] មាត្រា ៤៤ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នោះបង្ហាញខ្លួនមុខតុលាការជាន់ដំបូង ដែលដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនការ ។[32]

❖ **ក្នុងករណីដែលតំណាងអយ្យការសម្រេចថាមិនចោទប្រកាន់**

ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យឪពុកម្ដាយ ឬអាណាព្យាបាលវិញក្នុងករណីអនីតិជនមានអាយុក្រោម ១៤ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ ។[33] តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ តំណាងអយ្យការក៏អាចមិនធ្វើការចោទប្រកាន់បានដែរ ប្រសិនបើបទល្មើសនោះជាបទលហុ ឬមជ្ឈិម ដោយតំណាងអយ្យការពិចារណាជាបឋមទៅលើការបង្វែរ ។[34] នៅពេលដែលព្រះរាជអាជ្ញាសម្រេចបង្វែរ នោះព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។[35]

❖ **ការបំបែកសំណុំរឿង**

ប្រសិនបើតំណាងអយ្យការពិនិត្យសំណុំរឿងឃើញថា អំពើល្មើសដែលប្រព្រឹត្តនោះ មានសហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផងនោះ តំណាងអយ្យការអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នា ។[36]

### ៣.១.២.៤ ការបង្វែរក្នុងដំណាក់កាលតំណាងអយ្យការ

ក្នុងដំណាក់កាលអយ្យការក្រោយពីបានស្ដាប់ចម្លើយរួចហើយ ក្នុងករណីដែលពិនិត្យឃើញថាលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ ត្រូវបានបំពេញនោះព្រះរាជអាជ្ញាអាចធ្វើការពិចារណាជាបឋមទៅលើការផ្ទេររឿងក្ដីនេះចេញពីនីតិវិធីបានដោយអនុវត្តទៅតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជនដែលកំណត់ពីនីតិវិធីនៃការបង្វែរ និងអ្នកទទួលបន្ទុកក្នុងការបង្វែរ ។

វិធានការបង្វែរ គឺជាយន្តការទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាព ហើយក៏ជាយន្តការដំបូងដើម្បីគាំទ្រដល់កុមារមិនឲ្យប្រព្រឹត្តបទល្មើសជាថ្មីដែរ ។ ការបង្វែរមានគោលបំណងកាត់បន្ថយផលប៉ះពាល់ដែលកើតឡើង

---

[32] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[33] មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[34] មាត្រា ២៨ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[35] មាត្រា ២៨ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[36] មាត្រា ៣០ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ពីការផ្តន្ទាទោសក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយអនុវត្តវិធានការផ្សេងដែលសមស្របសម្រាប់កុមារដែលប្រព្រឹត្តបទល្មើស ។ ការបង្វែរទទួលស្គាល់ថា នៅពេលដែលកុមារត្រូវបានឃុំខ្លួន បើទោះជារយៈពេលខ្លីក៏ដោយ ក៏ពួកគេងាយនឹងប្រពឹត្តបទល្មើសជាថ្មី ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅពេលដែលពួកគេធំឡើង ។ ការសម្រេចយកវិធានការបង្វែរកុមារជំនួសឲ្យការឃុំខ្លួន ជួយកាត់បន្ថយការប្រព្រឹត្តបទល្មើសនៅពេលពួកគេពេញវ័យជួយដល់សហគមន៍ ជួយដល់ប្រព័ន្ធយុត្តិធម៌ និងកុមារខ្លួនឯង ។

ការបង្វែរមិនអាចអនុវត្តចំពោះបទល្មើសធ្ងន់ធ្ងរ និងជនល្មើសមិនរាងចាលបានទេ ។[37] អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។[38]

### ក. លក្ខខណ្ឌនៃការបង្វែរ

ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីការរៀបចំបង្កើតផែនការបង្វែ យើងគួរសិក្សាអំពីលក្ខខណ្ឌអប្បបរមានៃការបង្វែរ(ក១) និងលក្ខខណ្ឌវិថ្ថ័យសម្រាប់បង្វែរ(ក២) ជាមុនសិន ។

#### ក១. លក្ខខណ្ឌអប្បបរមានៃការបង្វែរ[39]

ច្បាប់យុត្តិធម៌អនីតិជនទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមដ៏សកម្មរបស់កុមារ និងស្ថាប័នដែលពាក់ព័ន្ធដើម្បីធានាឲ្យមានវិធានការបង្វែរទទួលបានជោគជ័យ ប៉ុន្តែដើម្បីបង្កើតវិធានបង្វែរបាន លុះត្រាតែចាំបាច់បំពេញតាមមាត្រា ៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងពីលក្ខខណ្ឌអប្បរមានៃការបង្វែរដែលមានដូចក្រោម៖

- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។
- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។
- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

[37] សូមមើល Link https://shorturl.at/jmv34 ទំព័រ ២៣៤

[38] មាត្រា ៦១ ស្តីពីច្បាប់ពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[39] មាត្រា ៦៣ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ ។

**ក២. លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការបង្វែរ**[40]

- កាលៈទេសៈនៃបទល្មើស

- ស្ថានភាពនៃបទល្មើស

- បុគ្គលិកលក្ខណៈអនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត

- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន

- ព្យសនកម្មរបស់ជនរងគ្រោះ និង

- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គមផងដែរ ។

បន្ទាប់ពីការបំពេញនូវលក្ខខណ្ឌអប្បបរមា និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបង្វែររួចហើយ អាជ្ញាធរដែលទទួលបន្ទុកបង្វែរត្រូវជ្រើសរើសវិធានការបង្វែរ ដែលត្រូវដាក់ឲ្យអនីតិជនបំពេញតួនាទីមានមួយ ឬច្រើនប្រភេទដូចជា៖[41]

- ចំណុចមួយ ឬច្រើនដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃត្រួតពិនិត្យតាមផ្លូវតុលាការ[42]
- ទៅសាលារៀនឲ្យបានទៀតទាត់តាមផែនការ ឬចំណាយពេលជាមួយគ្រួសារ ឬចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងថេរវេលាកំណត់មិនឲ្យលើស ៦ (ប្រាំមួយ) ខែ
- វិធានការបង្វែនោះ អាចឲ្យអនីតិជនធ្វើការងារសហគមន៍មិនលើស ១០០ (មួយរយ) ម៉ោងសម្រាប់អនីតិជន មានអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំឡើងទៅ ឬចូលរួមកម្មវិធីសហគមន៍ ឬ មណ្ឌលដែលមានប្រយោជន៍សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសារជាថ្មី

[40] មាត្រា ៦៥ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[41] មាត្រា ៦៥ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, មាត្រា ២២៣ ដល់មាត្រា ២៣០ និងសារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវជាប់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

- អនីតិជនអាចត្រូវបានអាជ្ញាធរទទួលបន្ទុកបង្វែដាក់ឲ្យស្នាក់នៅទីកន្លែងណាមួយក្នុងរយៈពេលកំណត់ជាក់លាក់
- ជុសជុលសំណងការខូចខាតជូនទៅជនរងគ្រោះវិញ និង
- រួមទាំងវិធានបង្វែរផ្សេងៗទៀត ដែលបំពេញគោលបំណងនៃការបង្វែរ ។

**ខ. ការអនុវត្តផែនការបង្វែរ**

ការរៀបចំផែនការបង្វែនេះជាបន្ទុករបស់ភ្នាក់ងារសង្គមកិច្ច ត្រូវធ្វើឡើងក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលបានដំណឹងអំពីដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ លើកលែងតែមានស្ថានភាពពិសេសពុំអាចជម្នះបាន ។[43] ជំហានបន្ទាប់ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរដែលទទួលបន្ទុកបង្វែរពិនិត្យ និងសម្រេច ហើយប្រសិនអាជ្ញាធរនោះយល់ស្រប និងមានការចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ តែបើមិនសម្រេចនោះទេ នឹងមានការបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំផែនការជាថ្មី ដែលមានរយៈពេល ១ ខែដូចគ្នា ។[44] ក្នុងអំឡុងពេលនៃការសម្រេចនេះ ភ្នាក់ងារសង្គមកិច្ចត្រូវសម្រេចលើកត្តាដូចជា៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម
- ក្រៅពីនេះក៏ត្រូវពិចារណាទៅលើអាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជនផងដែរ ។

បន្ទាប់មក ផែនការបង្វែរនឹងត្រូវអនុវត្តលើអនីតិជន ដោយត្រូវបានរ៉ាប់រងដោយភ្នាក់ងារ សង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែ ដើម្បីតាមដានពីវឌ្ឍនភាពនៃការរីកចម្រើនរបស់អនីតិជន រួចបញ្ជូនរបាយ

[43] មាត្រា ៦៦ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[44] មាត្រា ៦៨ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ការណ៍នេះ ទៅអាជ្ញាធរទទួលបន្ទុក និងចម្លងជូនមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ។[45] កាលដែលអនីតិជនមិនបានគោរពតាម កាតព្វកិច្ចក្នុងផែនការបង្វែរទេ នោះនាំឲ្យមានការបរាជ័យនៃការអនុវត្តផែនការនេះ ដែលនាំឲ្យអាជ្ញាធរទទួលបន្ទុកបង្វែរបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ ។

### ២.២ ដំណាក់កាលនៃការស៊ើបសួរ

ក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរនឹងបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញអំពីអត្ថិភាព និងនត្ថិភាពនៃបទល្មើសដែលប្រព្រឹត្តឡើងដោយអនីតិជននោះ ដោយចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ។[46] ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាពពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។[47]

#### ២.២.១ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ

នីតិវិធីដែលត្រូវធ្វើដំបូងនៅពេលដែលអនីតិជនបង្ហាញខ្លួនលើដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជនហើយប្រាប់អនីតិជនឱ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។ បន្ថែមពីនេះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬទៅអ្នកដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យនេះផងដែរ ។[48]

#### ២.២.២ ការស្តាប់ចម្លើយរបស់ចៅក្រមស៊ើបសួរ

ចំពោះ(នីតិវិធីនៃការស្តាប់ចម្លើយរបស់អនីតិជន)[49] គឺមិនមានលក្ខណៈខុសប្លែកពីនីតិវិធីនៃការស្តាប់ចម្លើយរបស់ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌នោះទេ ប៉ុន្តែក្នុងករណីនេះក៏មានវត្តមានរបស់ក្រឡាបញ្ជីដែលជាសេនាធិការរបស់ចៅក្រម និងត្រូវតែមានការស្តាប់ចម្លើយផ្ទាល់ពីសំណាក់ចៅក្រមស៊ើបសួរ ។[50] ចៅក្រម

---

[45] មាត្រា ៦៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[46] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[47] មាត្រា ៣៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[48] មាត្រា ៣៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[49] មាត្រា ៣៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[50] សារណារបស់និស្សិត ឈ្មោះ អ៊ុត សុជានីត និងអ៊ំ ស៊ិនសារណោ ឆ្នាំ២០២១ ទំព័រទី ២៧

ស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយក្នុងករណីអវត្តមានមេធាវី និងត្រូវចេញលិខិតអញ្ជើញ កោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ បន្ថែមពីនេះប្រភេទនៃការបន្ទាន់ត្រូវតែចុះ និទ្ទេសនៅក្នុងកំណត់ហេតុ ។[51] ទាក់ទងទៅនឹងការឃុំខ្លួន វត្តមាន ឬអវត្តមានរបស់មេធាវីមិនរារាំងក្នុងការសម្រេចរបស់ចៅក្រមស៊ើបសួរអំពីការឃុំខ្លួន ឬមិនឃុំខ្លួនជាបណ្តោះអាសន្នទៅលើអនីតិជននោះឡើយ ។[52]

### ២.២.៣ អំណាចចៅក្រមស៊ើបសួរក្នុងការបង្វែរ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការអនុវត្តវិធានការបង្វែរនេះ ជាពិសេសក្នុងរឿងក្តីដែលមានជនត្រូវចោទជាអនីតិជន ។ ករណីដែលអនីតិជនត្រូវចោទប្រកាន់ថាបានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានស្ថានទម្ងន់ទោស ចៅក្រមស៊ើបសួរត្រូវពិចារណាជាអាទិភាពទៅលើការប្រើប្រាស់នូវវិធានការបង្វែរ មុននឹងប្រើនូវវិធានការផ្សេងពីនេះ ។[53]

### ២.២.៤ ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រោយពីមានការចោទប្រកាន់របស់តំណាងអយ្យការ ចៅក្រមស៊ើបសួរអាចដាក់អនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេល ។ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជំនួសឱ្យកាឃុំខ្លួនបណ្តោះអាសន្ន ព្រោះការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានចុងក្រោយដែលចៅក្រមស៊ើបសួរនឹងពិចារណាប្រើប្រាស់ទៅលើអនីតិជន ។[54] ប្រសិនបើចៅក្រមស៊ើបសម្រេចថាត្រូវដាក់អនីតិជននោះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ ចៅក្រមស៊ើបត្រូវអនុវត្តទៅតាមបទបញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមបន្ថែមចំណុចពិសេសមួយចំនួនដូចមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជនដូចជា៖

- ការដាក់ដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ ឬអ្នកមានអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកទំនុកបម្រុង ឬក្រុមគ្រួសារណាមួយសមស្រប
- ការដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងថែទាំក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទា និងការមើលថែទាំអនីតិជន

[51] មាត្រា ៣៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[52] មាត្រា ៣៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[53] សារណារបស់និស្សិត ឈ្មោះ ផល់ សុភ័ក្រទិទ្ធ និងសុវណ្ណ ថាវឌ្ឍន៍ ឆ្នាំ២០២១ ទំព័រទី ២៤
[54] មាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ❖ មិនឱ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- ❖ វិធានការផ្សេងទៀតដែលតុលាការយល់ថាសមស្រប ។[55]

### ២.២.៥ ការដោះលែងអនីតិជនឱ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឱ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ បន្ថែមពីនេះចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។ ក្រៅពីព្រះរាជអាជ្ញា អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជក៏អាចសុំឱ្យដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីក៏អាចដាក់ពាក្យសុំដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានផងដែរ បើមានការយល់ព្រមពីអនីតិជន ។ ចំពោះការស្នើសុំនេះ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។[56]

### ២.២.៦ ការចេញនូវដីកាដំណោះស្រាយបិទការស៊ើបសួរ

ក្រោយពីបញ្ចប់នីតិវិធីស៊ើបសួរ ចៅក្រមស៊ើបនឹងចេញនូវដីកាដំណោះស្រាយ ហើយមុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការប៉ានប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរគឺមាន ២ ប្រភេទគឺៈ

- ❖ **ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់**

ចៅក្រមស៊ើបសួរនឹងចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ បើសិនជារកឃើញថាអំពើប្រព្រឹត្តនោះស្ថិតក្នុងករណីដូចមានកំណត់ក្នុងមាត្រា ២៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ បន្ថែមពីនេះ អានុភាពនៃដីកាដំណោះស្រាយលើកលែងចោលការចោទប្រកាន់ គឺនាំឱ្យមានការដោះលែងអនីតិជនដែល

[55] មាត្រា ៤០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[56] មាត្រា ៤១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បានជាប់ឃុំ បើទោះបីជាមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។[57] តែប្រសិនបើលេចឡើងបន្ទុកថ្មី ការស៊ើបសួរនឹងបើកឡើងវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា ។[58]

❖ **ដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ**

ដោយផ្អែកទៅលើភស្តុតាងទាំងឡាយដែលរកបាន ហើយចៅក្រមស៊ើបសួរយល់ឃើញថាជនត្រូវចោទដែលជាអនីតិជននោះបានប្រព្រឹត្តបទល្មើសពិតមែន នោះចៅក្រមស៊ើបសួរនឹងចេញនូវដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ ដោយចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនការជំនុំជម្រះ ។[59]

## ២.៣ ដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ

សាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន គឺមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលមានជនជាប់ចោទជាអនីតិជន ។[60] តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ។[61]

### ២.៣.១ នីតិវិធីមុនពេលសវនាការ

មុនចាប់ផ្តើមសវនាការ តុលាការត្រូវធ្វើការពិនិត្យទៅលើរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព រួមទាំងស្ថានភាពសសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម នោះតុលាការត្រូវបង្គាប់ឱ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ ។[62]

---

[57] មាត្រា ៤២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[58] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[60] មាត្រា ៤៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[61] មាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[62] មាត្រា ៤៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ២.៣.២ នីតិវិធីសវនាការ

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នូវនីតិវិធីកុមារមេត្រី ។ បន្ថែមពីនេះ ក្នុងករណីពិសេសមេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីប្រឈមសមស្របណាមួយក្នុងការស្តាប់ចម្លើយ ។[63] រាល់ការពិភាក្សាដេញដោលរឿងក្តីអនីតិជនត្រូវតែធ្វើឡើងជាអសាធារណៈមានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ ។[64]

ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។[65] ម៉្យាងទៀតតុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ បន្ថែមពីនេះចម្លើយដែលបានមកពីការគំរាមកំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ ។[66]វិធានការបង្វែរក៏ត្រូវបានលើកយកមកពិចារណាក្នុងដំណាក់កាលនៃការជំនុំជម្រះ ដូចទៅក្នុងដំណាក់កាលព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ ។ ដោយចៅក្រមជំនុំជម្រះមានអំណាចក្នុងការអនុវត្តនូវវិធានការបង្វែរចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលជាប់ចោទពីបទលហុ បទមជ្ឈិម ឬបទមជ្ឈិមមានស្ថានទម្ងន់ទោស និងពិចារណាទៅលើលក្ខខណ្ឌអប្បបរមាដែលតម្រូវអោយបំពេញដោយអនីតិជនដើម្បីអាចអនុវត្តវិធានការនេះបាន ។

### ២.៣.៣ ការប្រកាសសាលក្រម

ការប្រកាសសាលក្រមអាចធ្វើឡើងនៅពេលសវនការ ក្រោយពីបានធ្វើការពិភាក្សាដេញដោល ឬនៅពេលដែលសវនាការសម្រេចលើកទៅពេលក្រោយ ។ ជាមួយគ្នានេះផងដែរ នីតិវិធីការប្រកាសសាលក្រមក៏មិនខុសនីតិវិធីពិភាក្សាដេញដោលដែរ ពោលគឺត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី

[63] មាត្រា ៤៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[64] មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[65] មាត្រា ៥៣ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[66] មាត្រា ៥៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

តែប៉ុណ្ណោះ ។ បន្ថែមពីនេះសាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ ។[67]

[67] មាត្រា ៥៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣

# វិធានការអនុវត្តទោសចំពោះអនីតិជន

ចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ហើយត្រូវបានគេជឿជាក់ថាពិតជាបានប្រព្រឹត្តបទល្មើសនោះមែន វិធានការទូទៅដែលត្រូវបានលើកយកមកអនុវត្តចំពោះអនីតិជនបាន គឺជាវិធានការទណ្ឌកម្មព្រហ្មទណ្ឌ និងវិធានការបង្វែរដូចដែលបានរៀបរាប់ខាងលើ ។ ដោយឡែកវិធានការទណ្ឌកម្មព្រហ្មទណ្ឌ គឺត្រូវតែជាវិធានការចុងក្រោយបំផុត ដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ដែលវិធានទាំងនោះរួមមាន៖ **ទណ្ឌកម្មព្រហ្មទណ្ឌដែលអនុវត្តចំពោះអនីតិជន** (៣.១) **ទោសដែលអនុវត្តចំពោះអនីតិជន** (៣.២) និង**ការអនុវត្តទោសចំពោះអនីតិជន** (៣.៣) ។

## ៣.១ ទណ្ឌកម្មព្រហ្មទណ្ឌដែលអនុវត្តចំពោះអនីតិជន

ជាគោលការណ៍អនីតិជនក៏អាចទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌដូចគ្នាទៅនឹងនីតិជនផងដែរ ។ ប៉ុន្តែអ្វីដែលខុសគ្នាពីនីតិជន នោះគឺរបបនៃទោសដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន គឺមិនដូចគ្នាទៅនឹងរបបនៃទោសដែលអនុវត្តចំពោះនីតិជនឡើយ ពោលគឺអនីតិជនមាននូវរបបគតិយុត្តពិសេសមួយដាច់ដោយឡែក ។ តាមរយៈរបបនៃទោសនេះ គឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីបញ្ញត្តិនៃមាត្រា **១៦០** ដល់មាត្រា **១៦៦** បន្ថែមពីនេះ ដោយហេតុថាអនីតិជនមានសមត្ថភាពយល់ដឹងនៃការប្រព្រឹត្តរបស់ខ្លួន នៅមានកម្រិតនៅឡើយ កាលបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃអនីតិជនតម្រូវតុលាការក៏អាចសម្រេចឱ្យអនីតិជនទទួលបាននូវការសម្រាលទោសផងដែរ ។

## ៣.២ ទោសដែលអាចអនុវត្តចំពោះអនីតិជន

គេសង្កេតឃើញថាទោស គឺមានការប្រែប្រួលទៅតាមបុគ្គលដែលបានប្រព្រឹត្តបទល្មើសហើយ ការប្រែប្រួលនេះទៀតសោត គឺនាំឱ្យគេថា អាចបណ្ដាលមកពីមូលហេតុនៃការវិវត្តរបស់ជនដែលបានប្រព្រឹត្តបទល្មើស ។ ដោយផ្អែកទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យក និងបែងចែកប្រភេទនៃទោសនេះជា ០៣ (បី) ប្រភេទគឺ៖

### ៣.២.១ មូលទោស

មូលទោស គឺជាទោសដែលគេយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ក្នុងនោះដែរមូលទោសត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌដែលរួមមានទោសដាក់

ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ ក្នុងករណីនេះដែរ បើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ និងត្រូវបានចៅក្រមពិនិត្យ និងពិចារណាទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជននោះឃើញថាមានលក្ខណៈតម្រូវគ្រប់គ្រាន់ហើយ ដូចនេះច្បាប់បានផ្តល់នូវឆន្ទានុសិទ្ធិដល់ចៅក្រមអំពីការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបាន ។ ក្នុងករណីដែលចៅក្រមសម្រេចផ្តន្ទាទោសចំពោះអនីតិជន ពោលគឺចៅក្រមត្រូវលើកយកនូវមូលទោសដែលមានចែងក្នុងបញ្ញត្តិនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌមកអនុវត្តលើអនីតិជននោះ ។

ឧទាហរណ៍៖ ៖ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០១ និង ០០នាទីរំលងអធ្រាត្រ ជនរងគ្រោះឈ្មោះ **ក** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិឥណ្ឌា បានជិះម៉ូតូចេញពីសណ្ឋាគារ លុះដើរដល់ចំណុចផ្លូវព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ជនរងគ្រោះក៏បានលើកទូរស័ព្ទដៃដើម្បីមើលផែនទី ស្រាប់តែមានជនត្រូវចោទចំនួន ០២នាក់ឈ្មោះ **ខ** ភេទប្រុសអាយុ ១៦ឆ្នាំ និងឈ្មោះ **គ** ភេទប្រុស អាយុ ១៦ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក SUZUKI NEX មកអែបស្តាំដៃជនរងគ្រោះ ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃម៉ាកសាំសុងកាឡាក់ស៊ីអ៊ី៧៣ ពណ៌បៃតង ពីជនរងគ្រោះបានសម្រេច រួចបណ្តាយឲ្យជនរងគ្រោះបាត់បង់ជីវិតភ្លាមៗ ដោយស្ថិតក្នុងករណីបែបនេះ ចៅក្រមប្រហែលជាមិនអាចពិចារណាដាក់ឱ្យប្រើប្រាស់វិធានការផ្សេងក្រៅពីការដាក់ទោសលើអនីតិជនរូបនោះទេ តែទោះបីជាមានការផ្តន្ទាទោសលើអនីតិជនបែបនេះក៏ដោយ ចៅក្រមមិនអាចសម្រេចផ្តន្ទាទោសអនីតិជនដូចទៅនឹងនីតិជនបានឡើយ ។

សម្រាប់មូលទោសដែលអនុវត្តចំពោះអនីតិជន គឺច្បាប់បានកំណត់នៅក្នុងមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដោយបានចែងអំពីមូលទោសដែលអនុវត្តចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ដូច្នេះកាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជន ដែលមានអាយុចាប់ពី ១៤ ដប់បួន (ឆ្នាំ) ឡើងទៅ មូលទោសនៃបទល្មើសដែលត្រូវចោទប្រកាន់ត្រូវបានបន្ថយ ក្នុងលក្ខខណ្ឌដូចតទៅ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ។ ឧទាហរណ៍៖ ឈ្មោះ ក ភេទប្រុស អាយុ ១៦ ឆ្នាំ បានប្រព្រឹត្តបទល្មើស ឃាតកម្មអចេតនា ដែលមានទោសបញ្ញតិពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ ។ បើយោងតាមបទបញ្ញតិនៃក្រមព្រហ្មទណ្ឌ ដោយជនល្មើសឈ្មោះ ក ជាអនីតិជន ចៅក្រមជំនុំជម្រះតម្រូវពិចារណាទៅលើអាយុ និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនោះ ត្រូវបន្ថយពាក់កណ្តាល និងអតិបរមានៃទោសដាក់ពន្ធនាគារ ៣ឆ្នាំ មកត្រឹម ១ឆ្នាំ ៦ខែវិញ ។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។ ឧទាហរណ៍៖ ជនសង្ស័យឈ្មោះ **ក** ភេទប្រុស អាយុ ១៦ឆ្នាំ បានរៀបចំគម្រោងពួនស្ទាក់ជនរងគ្រោះឈ្មោះ **ខ** ដែលជាសត្រូវនឹងគ្នាព្រោះជនរងគ្រោះឈ្មោះ **ខ** ធ្លាប់មានទំនាស់និងជនសង្ស័យ លុះមានឱកាសមកដល់ជនសង្ស័យបានយកកាំបិតមកចាក់សម្លាប់ជនរងគ្រោះបណ្ដាយឲ្យស្លាប់ភ្លាមៗ នៅនឹងកន្លែងហេតុ ។ ដោយផ្អែកតាមអង្គហេតុនេះ អំពើប្រព្រឹត្តខាងលើជាបទល្មើស "ឃាតកម្មគិតទុកជាមុន" ដែលក្នុងករណីនេះ អតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត ត្រូវបន្ថយមកត្រឹម ២០ (ម្ភៃ) ឆ្នាំ ដូច្នេះដោយយោងទៅលើមូលហេតុអាយុនៃជនល្មើស ហើយតុលាការមិនអាចប្រកាសទោសលើសពីនេះបានទេ ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាលប្រសិនបើអប្បបរមានោះ លើសពី ១ (មួយ) ។ ឧទាហរណ៍៖ ក្នុងករណីដែលទោសជាប់ពន្ធនាគារ ត្រូវទទួលរងគឺ ៤ (បួន) ថ្ងៃ ដូចនេះអប្បបរមាចំពោះបទលហុអនីតិជនត្រូវទទួលរង គឺ ២ (ពីរ) ថ្ងៃជាអប្បបរមា ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។ ឧទាហរណ៍៖ ឈ្មោះ **ក** អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ បានប្រព្រឹត្តបទល្មើសលួច ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល បើយោងតាមក្រមព្រហ្មទណ្ឌ ។ នៅក្នុងករណីនេះទោសដែលត្រូវផ្ដន្ទាទោសចំពោះអនីតិជនត្រូវបន្ថយទាំងអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ផងដែរ ។ ដូច្នេះទោសដែលត្រូវយកមកអនុវត្តចំពោះអនីតិជន គឺទោសដាក់ពន្ធនាគារ ពីបទលួចដែលត្រូវផ្ដន្ទាទោសពី ៣ (បី)ខែ ទៅ ១(មួយ)ឆ្នាំ ៦(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន)រៀល ទៅ ៣.០០០.០០០ (បី លាន) រៀល ។

### ៣.២.២ ការប្រកាសទោសបន្ថែម

ទោសបន្ថែម សំដៅដល់ប្រភេទទោសមួយដែលបន្ថែមទៅលើមូលទោស ។ ក្នុងន័យនេះដែរជាទូទៅ នៅពេលដែលចៅក្រមប្រកាសអំពីមូលទោស ហើយក្នុងករណីដែលលក្ខខណ្ឌច្បាប់ចែងថា អនុញ្ញាតឱ្យមានការផ្ដន្ទាទោសបន្ថែមទៀតនោះ ចៅក្រមអាចសម្រេចទោសបន្ថែមទៅលើមូលទោសនោះទៀតបាន ។ ប៉ុន្តែបើយោងតាមមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌទោសបន្ថែមដែលអាចអនុវត្តចំពោះអនីតិជនបាន គឺមានត្រឹមតែ ៥ ប៉ុណ្ណោះ ហើយក្នុងចំណោមទោសបន្ថែមទាំងនេះមានទោសបន្ថែមទី៤ គឺរឹបអូសនូវទ្រព្យសម្បត្តិដែលមានទំនាក់ទំនងជាមួយនឹងបទល្មើស ចំណែកឯទោសបន្ថែមទី៥វិញ គឺគ្រាន់តែជាការហាមឃាត់មិនឱ្យកាន់កាប់គ្រាប់រំសេវ ឬប្រដាប់អាវុធ និងគ្រឿងផ្ទុះប៉ុណ្ណោះ ។

### ៣.២.៣ ការងារសហគមន៍

ទោសការងារសហគមន៍ដែលអនុវត្តចំពោះអនីតិជន គឺមានលក្ខណៈខុសប្លែកគ្នាពីទោសការងារសហគមន៍ដែលអនុវត្តចំពោះនីតិជន ។ យោងតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌមាត្រា ១៦២ លក្ខខណ្ឌដែលអាចអនុវត្តទោសការងារសហគមន៍ចំពោះអនីតិជនបាន គឺលុះត្រាតែៈ

- អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ប៉ុន្តែថេរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។
- ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់ក្នុងនៅក្នុងសង្គមវិញ ។

### ៣.២.៤ ស្ថានសម្រាលទោសចំពោះអនីតិជន

យោងតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ គឺតុលាការអាចសម្រេចឱ្យជនជាប់ចោទទទួលបាននូវស្ថានសម្រាលទោស ។ ស្ថានសម្រាលទោសខាងលើនេះអាចយកទៅអនុវត្តលើគ្រប់បទល្មើសបានទាំងអស់ ក្នុងករណីដែលកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទដែលតម្រូវឱ្យតុលាការសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។ ក្នុងករណីដែលតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោសអប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅៈ

១. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

២. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំនោះអប្បបរមាត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ)ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

៥. អប្បបរមានៃទោសពិន័យត្រូវបន្ថយពាក់កណ្តាល ។ សូមបញ្ជាក់ថានេះ គឺជាខ្នាតមួយដែលច្បាប់បានធ្វើការកម្រិត និងបញ្ញត្តិទុកសម្រាប់ឱ្យចៅក្រមយកទៅអនុវត្តលើករណីដែលអនីតិជនត្រូវទទួលបាននូវស្ថានសម្រាលទោស ។ មូលហេតុដែលច្បាប់បានពង្រីកដែនអនុវត្តនូវស្ថានសម្រាលទោសទៅដល់អនីតិជនបែបនេះ ព្រោះថានីតិករបានពិចារណាទៅលើអនីតិភាពនៃអនីតិជននេះឯង ដោយក្នុងគោលបំណងដើម្បីឱ្យអនីតិជនអាចទទួលបាននូវប្រយោជន៍គ្រួតគ្នាពីការកាត់បន្ថយទោសដោយស្វ័យប្រវត្តិ និងមានអានុភាពនៃការអនុវត្តដោយចៅក្រមនូវស្ថានសម្រាលទោសដូចគ្នាទៅនឹងខ្នាតដែលបានកម្រិតខាងលើ ។

គួរបញ្ជាក់ផងដែរថា ទោះបីតុលាការរកឃើញថាអនីតិជន នោះបានប្រព្រឹត្តបទល្មើសដដែល ដោយស្ថិតក្នុងលក្ខខណ្ឌនៃការមិនរាងចាលក៏ដោយ តុលាការមិនអាចអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលបានដែរ ពោលគឺអនីតិជននោះនៅតែត្រូវទទួលបាននូវស្ថានសម្រាលទោសដដែល ។ បន្ថែមពីនេះទៀតបទបញ្ញត្តិ ស្តីពីការមិនរាងចាល មិនត្រូវលើកយកមកអនុវត្តលើអនីតិជនបានឡើយ ។[68]

### ៣.៣ ការអនុវត្តទោសចំពោះអនីតិជន

ការអនុវត្តទោស គឺជាដំណាក់កាលដែលតុលាការធ្វើការផ្តន្ទាទោសទៅលើជនល្មើស ហើយនេះក៏ជាវិធានការចុងក្រោយ ដែលត្រូវយកមកអនុវត្តចំពោះជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ ។ យោងតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ការអនុវត្តទោសចំពោះអនីតិជនគឺធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទាដល់អនីតិជនតែប៉ុណ្ណោះ ដែលមានគោលបំណងក្នុងការបណ្តុះបណ្តាល ការថែទាំ ការការពារ ការអប់រំ ដើម្បីឱ្យអនីតិជនចូលទៅរួមរស់ក្នុងសង្គមវិញ ។ យ៉ាងណាមិញ អនីតិជនក៏ត្រូវទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌដូចនីតិជនទូទៅដែរ ក៏ប៉ុន្តែមានលក្ខណៈធូរស្រាលជាង ពោលគឺអនីតិជនទទួលបាននូវរបបគតិយុត្តិពិសេសមួយ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១៦០ ដល់មាត្រា ១៦៦ ។

#### ៣.៣.១ ការពិន័យចំពោះអនីតិជន

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទដែលស្ថិតក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងទៀតដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស ពោលគឺសំដៅទៅលើទោសមួយប្រភេទដែលមានគោលដៅធ្វើឱ្យជនល្មើសនោះរាងចាលតែម្តង ។[69] ដូច្នេះ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស

[68] មាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69] សៀវភៅទោសព្រហ្មទណ្ឌ លោក កៅ សីហា ទំព័រទី ៤៤

ចៅក្រមអាចប្រកាសនូវទោសពិន័យទៅលើអនីតិជននោះ ហើយផលនៃទោសពិន័យត្រូវបង់ចូលថវិការដ្ឋ ។[70] បន្ថែមពីនេះ ជនល្មើសក៏ត្រូវបង់នូវសំណងចំពោះការខូចខាតចំពោះបណ្តឹងរដ្ឋប្បវេណី និងជម្ងឺចិត្តផងដែរ ប្រសិនបើមានការទាមទារពីជនរងគ្រោះ ។[71] ក៏ប៉ុន្តែ ដោយសារតែជនល្មើសជាអនីតិជន ហេតុនេះចំពោះសំណងរដ្ឋប្បវេណីគឺតម្រូវឱ្យបុគ្គលដែមានករណីកិច្ចដែលច្បាប់បានកំណត់ក្នុងការត្រួតពិនិត្យអនីតិជន ត្រូវទទួលខុសត្រូវដោយសាមគ្គីជាមួយអនីតិជនចំពោះការខូចខាតរបស់អ្នកដ៏ទៃ ដែលបង្កឡើងដោយអនីតិជននោះ ។[72]

### ៣.៣.១.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ

ចំពោះនីតិវិធីនៃការដាស់តឿនឱ្យបង់ប្រាក់ពិន័យចំពោះអនីតិជន ក៏មិនខុសពីនីតិវិធីដែលអនុវត្តលើនីតិជនដូចមានចែងក្នុងមាត្រា ៥២៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌដែរ គឺក្នុងករណីដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់នោះទេ អង្គភាពរតនាគារត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអមនៃអយ្យការអមសាលាដំបូង ហើយព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់សម្រាប់ឱ្យទណ្ឌិតដែលជាអនីតិជនទៅធ្វើការបង់ប្រាក់ពិន័យ ។ ចំពោះរយៈពេលដែលបានកំណត់ គឺមិនអាចតិចជាង ១០ ថ្ងៃឡើយ ហើយការជូនដំណឹងនេះ គឺចាំបាច់ត្រូវតែធ្វើដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលវាត្រូវធ្វើឡើងជាកំណត់ហេតុ ហើយត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតស្នាមម្រាមដៃ (ទណ្ឌិតមិនចេះចុះហត្ថលេខា) ។[73] ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿនឲ្យទណ្ឌិតដែលជាអនីតិជនបង់ប្រាក់បែបនេះក៏ដោយ ក្នុងករណីដែលអនីតិជននោះនៅតែមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជននោះឡើយ ។

### ៣.៣.១.២ ការរួចខ្លួនពីការបង្ខំដល់រូបរាងកាយ

ដើម្បីធានាដល់ការបង់ប្រាក់ពិន័យ គឺត្រូវតម្រូវឲ្យមានវិធានការពីរ ដែលលើកមកអនុវត្ត គឺការរឹបអូស និងការបង្ខំដល់រូបកាយ ដែលការដកហូតទ្រព្យសម្បត្តិ គឺត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ចំណែកឯការបង្ខំដល់រូបរាងកាយត្រូវអនុវត្តតាមបទបញ្ញត្តិចាប់ពីមាត្រា ៥២៣ រហូតដល់មាត្រា ៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ លើសពីនេះទៅទៀត ការបង្ខំដល់រូបកាយអាចធ្វើទៅបាន លុះត្រាតែទណ្ឌិតនោះមានចេតនាគេចវេសមិនព្រមបង់ប្រាក់ពិន័យ ឈានរហូតដល់ការបង្ខំដល់រូបរាងកាយ ដើម្បីទាមទារប្រាក់ពិន័យ

[70] មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១១

[71] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[72] មាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[73] មាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បើទោះបីជាទណ្ឌិតលើកសំអាងថាខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យក៏ដោយ ។[74] ការបកស្រាយបែបនេះ ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់បុគ្គលដែលមានជីវភាពក្រីក្រដែលមិនមានលទ្ធភាពបង់ប្រាក់ពិន័យប្រាកដមែន ដែលអាចទទួលរងនូវការចាប់ដាក់ពន្ធនាគារដោយសារតែមូលហេតុនេះ ។ ដូច្នេះថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងដាក់លាក់តម្រូវឲ្យមានការគេចវេសដោយចេតនាក្នុងការបង់ប្រាក់ពិន័យ ដើម្បីអាចបង្ខំដល់រូបរាងកាយក៏ដោយ ក៏គួរគប្បីកំណត់យុទ្ធសាស្ត្រនូវលក្ខខណ្ឌនេះ ដើម្បីធានាឲ្យមានការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែរ ។[75] យ៉ាងណាមិញ ច្បាប់ក៏បានបញ្ញត្តិដាក់លាក់ផងដែរថា ការបង្ខំដល់រូបរាងកាយ គឺមិនអាចអនុវត្តទៅលើទណ្ឌិតជាអនីតិជនបានឡើយ ។[76]

### ៣.៣.២ ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា

#### ៣.៣.២.១ ការអនុវត្តទោសក្នុងពន្ធនាគារ

ពន្ធនាគារ សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ឃុំឃាំងជនល្មើស តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។[77] ការដាក់ពន្ធនាគារអនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការចុងក្រោយបង្អស់ ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ ។[78]

❖ **សិទ្ធិជាមូលដ្ឋានរបស់អនីតិជនអំឡុងពេលអនុវត្តទោសក្នុងពន្ធនាគារ**[79]

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្មរួមមាន ការដាក់ឱ្យនៅឯកា ការដាក់កំហិត ឬ បដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្ម ដោយបង្ខំ

[74] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពុណ្ណារិទ្ធិ ទំព័រទី ៤៥១
[75] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពុណ្ណារិទ្ធិ ទំព័រទី ៤៤៨
[76] មាត្រា ៥៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[77] មាត្រា ៤ ចំណុច ១ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១
[78] មាត្រា ៣៧ (ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
[79] មាត្រា ៨០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិទទួលបានវិធានការដាក់ពិន័យ ដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុងអំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ឬការដោះលែង ទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខលក្ខណៈឯកជនពីសមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធិភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

❖ **ការទុកដាក់អនីតិជនក្នុងមន្ទីរឃុំឃាំង**

ការឃុំឃាំងក្នុងពន្ធនាគារ គឺជានីតិវិធីមួយដែលធ្វើការឃុំអនីតិជនឱ្យជាប់ឃុំឃាំងក្នុងបន្ទប់ឃុំឃាំងហើយការដែលឃុំឃាំងនេះ ត្រូវបានបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំនីមួយៗនោះផងដែរ ។ ជនដែលជាប់ឃុំសំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំ ខ្លួនក្នុងពន្ធនាគារ តាមដីកាឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការទេ ។[80] ជនជាប់ឃុំជាអនីតិជនត្រូវបំបែកពីជនជាប់ឃុំដែលជានីតិជន ហើយជនជាប់ឃុំដែលជាជនត្រូវចោទជនជាប់ចោទ និងពិរុទ្ធជនត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត ។ ក្រៅពីនេះជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកជា ជនជាប់ឃុំជាបុរស ។[81] ចំពោះជនជាប់ឃុំដែលមានជំងឺឆ្លងត្រូវដាក់បំបែកដាច់ដោយឡែកពីជនជាប់ឃុំដទៃទៀតផងដែរ ។ ការបង្ខិតបង្ខំ ការធ្វើបាបរូបរាងកាយ ឬ

[80] មាត្រា ៤ ចំណុច ៣ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[81] មាត្រា ២៦ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

ប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។[82]

### ៣.៣.២.២ ការអនុវត្តទោសក្នុងមណ្ឌលយុវនីតិសម្បទា

យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបង្ហាញថា ការគ្រប់គ្រងអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបានចែកជាបីផ្នែកដាច់ដោយឡែកពីគ្នាដែលមានដូចជា៖[83]

ក. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន

ខ. ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា

គ. ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

ម្យ៉ាងវិញទៀត ក្រៅពីការបែងចែកផ្នែកសម្រាប់គ្រប់គ្រងអនីតិជន ក៏ត្រូវរក្សាអនីតិជននៅដោយឡែកពីនីតិជនផងដែរ ពោលគឺត្រូវដាក់នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងៗគ្នាតាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់អនីតិជននោះ ។ ចំពោះអនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា ។ ក្នុងករណីអនីតិជនមានជំងឺឆ្លង ត្រូវនៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដោយឡែកពីអនីតិជនផ្សេងៗជាកំហិត។ ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូល ១៨ឆ្នាំ ក្នុងពេលបាននឹងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងយុវនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ឆ្នាំ ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជនវិញ ។ ចំពោះបែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[84]

#### ❖ ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិត

[82] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[83] មាត្រា ៧៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[84] មាត្រា ៨០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួន ត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។ យន្តការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលឃុំនីតិសម្បទានានាបានគ្រប់ពេល ។ លើសពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចជាៈ[85]

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដែលស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ អាយុ របស់អនីតិជន

- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល

- សិក្សាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡាកម្សាន្ត និងសម្រាកពីការងារ

- សុខភាពផ្លូវកាយ សុខភាពផ្លូវចិត្តឱ្យបានសមស្រប

- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវការបញ្ចូលទៅក្នុងសំណុំរឿងអនិតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត

- សេវាផ្សេងៗទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ លើកទឹកចិត្តអោយមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនមានការអភិវឌ្ឍសក្តានុពលរបស់ខ្លួន ក្លាយជាពលរដ្ឋល្អប្រសើរម្នាក់ក្នុងសង្គម និងជួយសង្គមឲ្យបានល្អប្រសើរត្រឡប់មកវិញបន្ទាប់ពីមានការដោះលែងរួចហើយ ។

[85] មាត្រា ៨១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយ ប្រធានបទខាងលើរួចមក យើងអាចសង្កេតឃើញថា ការប្រព្រឹត្តបទល្មើសអ្វីមួយរបស់អនីតិជនដែលប្រាសចាកពីច្បាប់នោះ មិនអាចចៀសផុត ឬគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ពោលគឺអនីតិជនក៏ត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌដូចជានីតិជនដែរ ។ ទោះបីអនីតិជនត្រូវទទួលនូវទណ្ឌកម្មក៏ពិតមែន តែអនីតិជនគឺនៅតែជាកុមារដែលតម្រូវឱ្យច្បាប់មានការការពារ ព្រោះថាកុមារគឺជាជនដែលកំពុងស្ថិតនៅក្នុងការវិវិឌ្ឍន៍ចិត្តគំនិត ឬការយល់ដឹងប្រាជ្ញាស្មារតី និងការគិតពិចារណារបស់ពួកគេ គឺនៅក្មេងខ្ចីនៅឡើយ ។ ដូចនេះ ចៅក្រម និងតំណាងអយ្យការ មុនធ្វើការសម្រេចចិត្តចោទប្រកាន់ទៅលើអនីតិជន ត្រូវគិតពិចារណាជាច្រើនដូចជា អប្បកិរិយា កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈ របស់អនីតិជននោះ ឲ្យបានច្បាស់លាស់ជាមុនថា តើអនីតិជននោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដែរឬទេ ? ព្រោះថាប្រសិនបើគ្មានការពិចារណាឲ្យបានល្អិនល្អន់ ទាក់ទងនឹងការផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជននេះទេ វានឹងអាចជះឥទ្ធិពលអាក្រក់ទៅដល់ពួកគេនៅថ្ងៃអនាគត ។ ក្នុងន័យនេះ គឺចង់ឱ្យតុលាការមុននឹងសម្រេចផ្តន្ទាទោសទៅលើអនីតិជន គួរតែគិតទៅលើឧត្តមប្រយោជន៍របស់អនីតិជនជាចម្បង ស្របទៅតាមគោលការណ៍ដែលមានចែងនៅក្នុងបទដ្ឋានជាតិ និងអន្តរជាតិ ក៏ដូចជាលិខិតតុបករណ៍អន្តរជាតិនានា ដែលកំណត់ថា អនីតិជននៅពេលដែលប្រព្រឹត្តបទល្មើស ត្រូវតែជាកម្មវត្ថុនៃវិធានការតាមដាន វិធានអប់រំ វិធានការការពារ និងវិធានឧបត្ថម្ភ ។ ក្រៅពីវិធានទាំងនេះ យើងក៏មានវិធានការបង្វែរផងដែរ ដែលបានផ្តល់នូវអត្ថប្រយោជន៍ដល់អនីតិជនយ៉ាងច្រើនដូចជា បានធ្វើឲ្យជននោះបានយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះ ធ្វើការកែប្រែកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអ្វីដែលសំខាន់នោះ គឺមិនមានការដកហូតនូវសិទ្ធិសេរីភាព ឬឃុំឃាំងជននោះក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។ ទោះបីជាយ៉ាងនេះក៏ដោយ គេមិនអាចឱ្យជនដែលបានប្រព្រឹត្តអំពើមិនគប្បីទៅលើជនដទៃឱ្យរួចផុតពីការទទួលទោសទណ្ឌបានឡើយ ពីព្រោះថាអំពើដែលគេបានធ្វើនោះគឺជាអំពើដែលផ្ទុយទៅនឹងច្បាប់ និងជាអំពើមួយដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។ ហេតុដូច្នេះ គេត្រូវតែទទួលយកចំពោះការអនុវត្តទោសនៅក្នុងពន្ធនាគារ ឬមណ្ឌលកែប្រែណាមួយដែលច្បាប់បានកំណត់ គ្រាន់តែការអនុវត្តទោសចំពោះពួកគេ គឺមានលក្ខណៈស្រាលជាងទណ្ឌិតដទៃដែលជានីតិជន ។ ហើយម្យ៉ាងវិញទៀត គឺដើម្បីឲ្យប្រជាពលរដ្ឋមានទំនុកចិត្តទៅលើប្រព័ន្ធយុត្តាធិការនៅកម្ពុជាផងដែរ ថាស្ថាប័នតុលាការនៅកម្ពុជាពិតជាមានសុក្រិតភាព និងយុត្តិធម៌ប្រាកដមែន ។

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីឱ្យការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ស្របទៅតាមស្មារតីក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ពិសេសដែលពាក់ព័ន្ធនឹងអនីតិជន ប្រកបទៅដោយប្រសិទ្ធិភាព និងយុត្តិធម៌ ។

នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថា ទោះបីជាច្បាប់បានការពារ និងផ្តល់ជាឧត្តមប្រយោជន៍នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌដែលមានជនល្មើសជាអនីតិជនក៏ដោយ យើងតែងតែឃើញអ្នកមានសមត្ថកិច្ចក្នុងរឿងនេះ នៅតែអនុវត្តមិនទាន់ខ្ជាប់ខ្ជួន និងមាននូវភាពខ្វះខាតនៅឡើយ ។ ហេតុដូច្នេះ ដើម្បីឱ្យការអនុវត្តពាក់ពន្ធទៅនឹងអនីតិជនក្នុងរឿងព្រហ្មទណ្ឌ ប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌តាមច្បាប់ ។ យើងខ្ញុំសូមផ្តល់ជាមតិយោបល់ មួយចំនួនដូចខាងក្រោម៖

- ពង្រីកការផ្សព្វផ្សាយផ្នែកច្បាប់ និងសិទ្ធិ របស់អនីតិជនឱ្យបានទូលំទូលាយទៅស្ថាប័នពាក់ព័ន្ធ រួមទាំងប្រជាពលរដ្ឋ ដើម្បីឱ្យមានការយល់កាន់តែស៊ីជម្រៅ

- បង្កើនជំនាញតុលាការ និងមន្ត្រីមានសមត្ថកិច្ច ក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌរបស់អនីតិជន

- ពង្រឹងនូវការអនុវត្តនីតិវិធី ក៏ដូចជាធានាឲ្យបានថានៅគ្រប់ដំណាក់កាលដែលប្រព្រឹត្តទៅ គឺមានភាពស្របតាមលក្ខណៈនីតិវិធីកុមារមេត្រី

- ជម្រុញ និងលើកទឹកចិត្តទៅដល់ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធទាំងឡាយ ឲ្យមានការពិចារណាជាបឋមទៅលើការប្រើប្រាស់នូវវិធានការបង្វែរមុននឹងឈានដល់ការសម្រេចដាក់នូវទណ្ឌកម្មព្រហ្មទណ្ឌ ។

## ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥
- តាមអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុម័តដោយអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
- សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវជាប់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

## ឯកសារសៀវភៅ និងអត្ថបទពាក់ព័ន្ធ

- នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពុណ្ណារិទ្ធិ
- នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ ហ៊ី សោភា
- សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ
- នីតិព្រហ្មទណ្ឌទូទៅ, លោក កៅ សីហា

- សៀវភៅទោសព្រហ្មទណ្ឌ លោក កៅ សីហា
- សារណារបស់និស្សិត ឈ្មោះ គា ភារ៉ា និងហេង វឌ្ឍនៈ ឆ្នាំ២០១៧
- សារណារបស់និស្សិត ឈ្មោះ អ៊ុត សុផានីត និងអ៊ំ ស៊ិនសារណា ឆ្នាំ២០២១
- សារណារបស់និស្សិត ឈ្មោះ ផល់ សុភ័ក្ររិទ្ធ និងសុវណ្ណ ថាវឌ្ឍន៍ ឆ្នាំ២០២១
- អត្ថបទស្តីអំពី ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិអនីតិជន
  https://shorturl.at/jmv34

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ [redacted]
ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២
លេខ:....................អ.យ.ណ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញរបាយការណ៍សំយោគលេខៈ [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ផែនការងារនគរបាលព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្មតថាៈ

១-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស កើតឆ្នាំ២០០២, ជនជាតិខ្មែរ, កាន់សាសនាព្រះពុទ្ធ, ទីកន្លែងកំណើតនៅឃុំពោធិ៍រាម ស្រុកពារាំង ខេត្តព្រៃវែង, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល [redacted], មុខរបរ មិនពិតប្រាកដ, ប្រពន្ធឈ្មោះ [redacted] "រ.ស", ឳពុកឈ្មោះ [redacted] "រ.ស", ម្តាយឈ្មោះ [redacted] "រ.ស", កម្រិតវប្បធម៌ថ្នាក់ទី ៦ថ្មី, ទោសពីមុន គ្មាន ។ (ឃាត់ខ្លួន

២-នាមត្រកូល និងនាមខ្លួន [redacted] ភេទប្រុស កើតឆ្នាំ២០១០, ជនជាតិខ្មែរ, កាន់សាសនាព្រះពុទ្ធ, ទីកន្លែងកំណើតនៅភូមិ១២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ, មានទីលំនៅមុខពេលឃាត់ខ្លួនស្នាក់នៅផ្ទះ [redacted] សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ , មុខរបរ នៅផ្ទះ,ឳពុកឈ្មោះ [redacted], ម្តាយឈ្មោះ [redacted] "រ", កម្រិតវប្បធម៌ថ្នាក់ទី ៣ថ្មី, ទោសពីមុន គ្មាន ជាអនីតិជន ។ (ក្រៅឃុំ

៣-ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៧ឆ្នាំ (គ្មានអត្តសញ្ញាណ។ (គេ ចខ្លួន

**បានប្រព្រឹត្តអំពើដូចតទៅ[1]៖** កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ២០ និង ១០ នាទី នៅចំណុចផ្លូវ [redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ២១ឆ្នាំ បានឈប់ទិញម្ហូប ហើយបានដកទូរស័ព្ទចំនួន ០២គ្រឿងម៉ាក IPHONE 11PRO MAX និងម៉ាកគូកលគីកសេល មកកាន់នៅដៃខាងស្តាំ ហើយក៏មានជនសង្ស័យចំនួន ០៣នាក់ រួមមានៈ ១.ឈ្មោះ [redacted] ភេទប្រុស អាយុ កើតឆ្នាំ២០០២, ២.[redacted] ភេទប្រុស កើតឆ្នាំ២០១០ និង ៣.ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៧ឆ្នាំ ជិះម៉ូតូ ០១គ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផ្លាកលេខកណ្តាល ១T.2835 ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចបាននាំគ្នាជិះគេចខ្លួន ហើយត្រូវជនរងគ្រោះបានស្រែកចោរៗ ផ្អើរឆោឡោ ស្របពេលនោះក៏មានសមត្ថកិច្ចល្បាតឃើញទាន់ បានអន្តរាគមន៍ឃាត់ខ្លួនបានជនសង្ស័យចំនួន ០២នាក់មានឈ្មោះ [redacted] និងឈ្មោះ [redacted] នឹងដកហូតភស្តុតាងបានទូរស័ព្ទ ៤គ្រឿង ម៉ាក IPHONE 11PRO MAX, ម៉ាកគូកលគីកសេល, IPHONE 7PLUS ម៉ាក HUAWEI , និងម៉ូតូ ០១គ្រឿងជិះធ្វើសកម្មភាពយកទៅសាកសួរ ដោយជនសង្ស័យឈ្មោះ[redacted] ទើបតែមានអាយុ ១២ឆ្នាំ និងមានការឯកភាពពីព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សមត្ថកិច្ចបានឲ្យឈ្មោះ [redacted] ត្រូវជាជី

[1]សេចក្តីសង្ខេបអង្គហេតុ

ដូនរបស់ជនសង្ស័យរូបនេះធ្វើកិច្ចសន្យាជានាឲ្យជនសង្ស័យវិលត្រឡប់ទៅលំនៅឋានជាបណ្តុះអាសន្ន ក្រោយមកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនតាមនីតិវិធី តែម្តង ។

-អំពើប្រព្រឹត្តខាងលើជាបទល្មើសៈ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវលេខ[redacted] ក្រុមទី[redacted] ភូមិទួលសង្កែ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញៈ មាត្រា **៤៤** និងមាត្រា **១២៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឱ្យស្ថិតក្រោមការពិនិត្យ[2] ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ កើតឆ្នាំ២០០២ (ឃាត់ខ្លួន ។

២-ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ២០១០ ជាអនីតិជន (ក្រៅឃុំ ។

៣-ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៧ឆ្នាំ (គ្មានអត្តសញ្ញាណ។ (គេ ចខ្លួន

<u>ពីបទ</u>៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវលេខ៩០៧ ក្រុមទី៣ ភូមិទួលសង្កែ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3] ៖.........................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន លើជនសង្ស័យខាងលើ[4] ៖

ថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣

**តំណាងអយ្យការ**

[2]ឈ្មោះជនត្រូវចោទ

[3]កាតព្វកិច្ចណាមួយដែលបាននៅក្នុងមាត្រា ២២៣

[4]មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា២០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ:

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

លេខ:...........................

# ដីកាសន្និដ្ឋានស្ថាពរ

**យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: [redacted] ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ: [redacted] ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញលិខិតជូនដំណឹង ឬជូនព័ត៌មានស្តីពីការបិទការស៊ើបសួរលេខ: [redacted] ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ: [redacted] ព្រ.ទ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**<u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>**

**ឃើញថា[១]:**

១-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧, ជនជាតិខ្មែរ, កាន់សាសនាព្រះពុទ្ធ, ទីកន្លែងកំណើតនៅសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន ក្រុងភ្នំពេញ, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ [redacted] សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ, មុខរបរ សិស្ស, ឪពុកឈ្មោះ [redacted] "រ", ម្ដាយឈ្មោះ [redacted] កម្រិតវប្បធម៌ថ្នាក់ទី ៨ថ្មី, ទោសពីមុន គ្មាន, អនីតិជន ។ (ឃុំខ្លួន

២-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧, ជនជាតិខ្មែរ, កាន់សាសនាព្រះពុទ្ធ, ទីកន្លែងកំណើតនៅភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះ [redacted] ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ, មុខរបរ សិស្ស, ឪពុកឈ្មោះ [redacted] "រ", ម្ដាយឈ្មោះ [redacted] កម្រិតវប្បធម៌ថ្នាក់ទី ៩ថ្មី, ទោសពីមុន គ្មាន, អនីតិជន ។ (ឃុំខ្លួន

៣-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៤-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៥-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៦-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៧-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៨-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

៩-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

-ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមហាវិថីម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ**[1]៖ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០៣ និង ៣០ នាទីទៀបភ្លឺ ជនរងគ្រោះឈ្មោះ [redacted]និងមិត្តភក្តិ ០៣នាក់ បានជិះម៉ូតូ ០២គ្រឿង ទៅហូបបាយ ។ លុះពេលហូបបាយរួច បាននាំគ្នាជិះម៉ូតូត្រឡប់មកផ្ទះវិញនៅបុរីឡុងនី(ចំការដូង ពេលចេញដំណើរមកដល់ផ្លូវ៣១០ ក្បែរ សាលារៀនទួនហ្វា ស្រាប់តែមានជនត្រូវចោទមានចំនួន ០៩នាក់រួមមាន៖ ១.ឈ្មោះ [redacted]ហៅ ថ្ម , ២.ឈ្មោះ [redacted]ហៅ [redacted], ៣. ឈ្មោះ [redacted], ៤-ឈ្មោះ [redacted], ៥-ឈ្មោះ [redacted]៦-ឈ្មោះ [redacted], ៧-ឈ្មោះ [redacted], ៨-ឈ្មោះ [redacted]និងឈ្មោះ [redacted] បានជិះម៉ូតូ ០៣គ្រឿង(ម៉ូតូ០២គ្រឿង ម៉ាកស្កូកពី មិនចាំស្លាកលេខ និងម៉ូតូ ០១គ្រឿងម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ មិនចាំស្លាកលេខ ហើយក្រុម ជនត្រូវចោទបានជិះម៉ូតូដេញតាមប្រើខ្សែក្រវ៉ាត់ ដុំថ្មវាយ និងគប់លើជនរងគ្រោះ និងមិត្តភក្តិ ។ បន្ទាប់មកដោយមានការភិតភ័យជនរងគ្រោះបានជិះដល់លើផ្លូវម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ក៏បានផ្តួលម៉ូតូ ០១គ្រឿងម៉ាកស្កូបពី ពណ៌ខ្មៅលាយខៀវ ស៊េរី២០២១ ស្លាកលេខ ភ្នំពេញ ១ន-៥៤០៦ របស់ខ្លួនចោល និងរត់ឲ្យគេជួយ ពេលនោះក្រុមជនត្រូវចោទក៏បានលើកម៉ូតូរបស់ជនរងគ្រោះជិះទៅបាត់ ។ រហូតដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ កម្លាំងជំនាញ អ.ហ ខណ្ឌបឹងកេងកង បានរកឃើញម៉ូតូជនរងគ្រោះ ត្រូវបានជនត្រូវចោទយកមកប្លុងចោលនៅចំណុចផ្សារលូ ផ្លូវ៣១០ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។ លុះមកដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ កម្លាំងជំនាញ អ.ហ ខណ្ឌបឹងកេងកង បានកំណត់មុខសញ្ញាជនត្រូវចោទ ក៏បានធ្វើការឃាត់ខ្លួនជនត្រូវចោទចំនួន ០២នាក់ ឈ្មោះ [redacted]ហៅ [redacted]នាំមកសាកសួរ រួចបញ្ជូនតាមនីតិវិធី តែម្តង ។

**<u>បានឃើញ</u>៖**

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted]ភេទប្រុស អាយុ ១៨ឆ្នាំ នៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរបានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនបានខ្ចីម៉ូតូរបស់បងប្រុសបង្កើតឈ្មោះ [redacted]ដើម្បីជិះទៅកម្មវិធីខួបកំណើតមិត្តភក្តិ ដោយចេញពីផ្ទះទៅម៉ោងជាង ០៨ នាទីយប់ បានទៅយកមិត្តភក្តិឈ្មោះ [redacted]នៅបុរីពិភពថ្មីចំការដូង រួចក៏ជិះទៅកម្មវិធីនៅកោះពេជ្រ រហូតដល់ម៉ោងប្រហែលជាម៉ោង០១ ទៅម៉ោង០២យប់ ក៏នាំគ្នាចេញពីខួបកំណើតមកផ្ទះវិញ មានគ្នាចំនួន០៤ នាក់ ជិះម៉ូតូចំនួន ០២គ្រឿង ខ្លួនជិះម៉ូតូដឹកឈ្មោះ [redacted]ចំណែកឯឈ្មោះ [redacted] ជិះម៉ូតូដឹកឈ្មោះ [redacted] មកដល់ចំណុចផ្លូវ ២៩៤ បាននាំគ្នាចូលញ៉ាំបាយស្រូប ប្រហែលរយៈពេលកន្លះម៉ោង ក៏នាំគ្នាជិះម៉ូតូទៅផ្ទះវិញ ។ ពួកខ្លួនជិះមកដល់ផ្លូវសាលារៀនទួនហ្វា ក៏បានឃើញមនុស្ស០១ ក្រុម មានគ្នាចំនួន០៩ នាក់ មានម៉ូតូចំនួន ០៣គ្រឿង អង្គុយលើម៉ូតូមើលមកពួកខ្លួន ហើយពួកខ្លួនក៏បានមើលទៅពួកវាវិញ តែខ្លួនមិនបានយកដុំថ្មគប់ទៅពួកវានោះទេ ចំណែកមិត្តភក្តិខ្លួន ខ្លួនមិនដឹងថាវាបានយកដុំថ្មគប់ទៅពួកនោះ ឬអត់ទេ ។ បន្ទាប់មកស្រាប់តែពួកអ្នកដែលអង្គុយមើលមុខខ្លួននោះ បាននាំគ្នាជិះម៉ូតូជិះដេញខ្លួន ហើយបានយកដុំថ្មគប់ត្រូវមិត្តភក្តិខ្លួនឈ្មោះ ថា ។ ខ្លួនជិះមកដល់ផ្លូវកែងស្តុប ៩៥ ពួកវាតាមទាន់ខ្លួន បានយកខ្សែក្រវ៉ាត់វាយខ្លួនត្រូវខ្នង និងដៃ ចំណែកឯមិត្តភក្តិត្រូវបានពួកវាវាយដែរ ប៉ុន្តែខ្លួនមិនដឹងថាគេវាយវាត្រូវកន្លែងណាខ្លះទេ ។ ពួកខ្លួនបានរត់ចោលម៉ូតូពួកវាក៏បានលើកម៉ូតូខ្លួនជិះទៅបាត់ ហើយខ្លួនក៏បានទូរស័ព្ទហៅមិត្តភក្តិមកយក ដើម្បីទៅប្តឹងសមត្ថកិច្ច ។ ស្អែកឡើងសមត្ថកិច្ចបានហៅឪពុកខ្លួនទៅមើលម៉ូតូនៅសាលាខណ្ឌ តែម៉ូតូរបស់ខ្លួនត្រូវបានគេដោះយកគ្រឿង ក្បាំងមុខ, ចង្កៀងមុខ,កុងទ័រ និងបានដូរគឿង អាយចូលវិញ បូម

---

[1] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់
(ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ

និងកង់ ។ ខ្លួនពុំដឹងថាអ្នកណាជាអ្នកវាយខ្លួន និងយកម៉ូតូខ្លួននោះទេ ដោយសារពួកវាមានគ្នាច្រើនយប់ងងឹតពេក ។ ខ្លួនពុំដែលធ្លាប់មានរឿងជាមួយពួកវា និងស្គាល់ពួកវានោះទេ ។ ក្នុងរឿងនេះខ្លួនសុំដកពាក្យបណ្តឹង និងមិនទាមទារសំណងទេ ដោយសារមិនចង់មានរឿងវែងឆ្ងាយតទៅទៀត ។ សុំឲ្យតុលាការប្រគល់ម៉ូតូម៉ាក HONDA SCOOPY-I ពណ៌ខៀវពាក់ផ្លាកលេខភ្នំពេញ 1IS -5406 ដែលជារបស់បងប្រុសខ្លួន ឈ្មោះ [redacted]។(ឯ.១/២៨, ២២/២

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted]ហៅ [redacted]ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧ នៅសមត្ថកិច្ច និងអយ្យការបានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ១៨ និង ០០នាទី ខ្លួនបានចេញពីផ្ទះ ណាត់គ្នាទៅអង្គុយលេងនៅផ្សារលើល្វ ផ្លូវ៣១០ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ មានគ្នាសរុបចំនួន ០៩នាក់ ជិះម៉ូតូ ០៣គ្រឿង(ម៉ូតូ ០២គ្រឿង ម៉ាកស្កូបពី និងម៉ូតូ ០១គ្រឿងម៉ាកហុងដាសេ១២៥ ក្នុងនោះមាន១-ខ្លួន ២-ឈ្មោះ[redacted]៣-[redacted]ហៅ [redacted]៤-[redacted] ៥[redacted]៦-[redacted] ៧-[redacted] ៨-[redacted]៩[redacted]។ លុះពេលអង្គុយលេងដល់ម៉ោងប្រហែល ០៣ និង០០នាទី ទៀបភ្លឺ ឈានចូលថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ស្រាប់តែមានមនុស្ស ០៤នាក់ ជិះម៉ូតូ ០២គ្រឿង(០១គ្រឿងម៉ាកស្កូកពី និង ០១គ្រឿងម៉ាក និច មកដល់ក្បែរក្រុមខ្លួន និងធ្វើសកម្មភាពគប់ដុំថ្មលើក្រុមខ្លួនបណ្តាលឲ្យត្រូវម៉ូតូម៉ាក ហុងដា សេ១២៥ រួចពួកគេនាំគ្នាជិះម៉ូតូ គេចខ្លួន បន្ទាប់មកខ្លួនបានជិះម៉ូតូដេញតាមពីក្រោយហូតដល់ផ្លូវម៉ៅសេទុង ផ្លូវ៩៥ ក៏តាមទាន់ហើយខ្លួនក៏បានហូតខ្សែក្រវ៉ាត់វាយលើពួកគេ ពេលនោះម្ចាស់ម៉ូតូបានផ្តួលម៉ូតូចោលរត់គេចខ្លួន ហើយឈ្មោះ [redacted] បានលើកម៉ូតូ ០១គ្រឿង របស់ជនរងគ្រោះ និងនាំគ្នាជិះគេចខ្លួនទៅផ្ទះរៀងៗ ខ្លួន ។ លុះដល់វេលាម៉ោងប្រហែល ១៤ និង ០០នាទី ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ [redacted]ហៅ[redacted]បានប្រាប់ខ្លួនថាឈ្មោះ [redacted] បានដោះយកគ្រឿងម៉ូតូរបស់ភាគីម្ខាងទៀតយកទៅលក់ ប៉ុន្តែមិនដឹងលក់នៅកន្លែងណានោះទេ បន្ទាប់មកនៅវេលាម៉ោងប្រហែល ២១ និង ៣០នាទី ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចបានចុះមកដល់ហៅខ្លួនមកផ្តល់ចម្លើយអំពីរឿងហេតុ តែម្តង ។(ឯ.១/១៩, ២

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted]ហៅ [redacted]ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧ នៅចៅក្រមស៊ើបសួរ បានឆ្លើយថាៈ ខ្លួនសុំបដិសេធចម្លើយនៅសមត្ថកិច្ច ដោយមូលហេតុសមត្ថកិច្ចមិនបានអានចម្លើយរបស់ខ្លួន ឲ្យខ្លួនស្តាប់នោះទេ មិនឲ្យខ្លួនអានចម្លើយខ្លួនឯង និងសុំបដិសេធចម្លើយខ្លួនត្រង់ចំណុចថា "ខ្លួនពិតជាបានប្រព្រឹត្តអំពើវាយយកម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន" ព្រោះពេលនោះភាគីម្ខាងទៀតជាអ្នកយកដុំថ្មគប់មកលើពួកខ្លួនមុន ហើយពួកខ្លួន ក៏បានជិះម៉ូតូដេញតាមវាយតបវិញ ដោយមិនមានបំណងចង់យកម៉ូតូរបស់ភាគីម្ខាងទៀតទេ ។ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៦ល្ងាច ខ្លួន និងឈ្មោះ [redacted] បានជិះម៉ូតូទៅលេងនៅផ្សារលើល្វ នៅផ្លូវ៣១០ សង្កាត់ទួលស្វាយព្រៃទី២ នៅកន្លែងតូបលក់ផ្លែឈើ(លក់ផ្លែឈើ២៤ម៉ោង របស់បងមិត្តភក្តិរបស់ខ្លួន ពេលនោះក៏មានមិត្តភក្តិធ្លាប់ស្គាល់គ្នាចំនួន ៥នាក់ទៀត មានឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ចំណែកអ្នកផ្សេងចំនួន ៤នាក់ទៀត ខ្លួនមិនធ្លាប់ស្គាល់នោះទេ ។ ពេលនោះពួកខ្លួនក៏នាំគ្នាអង្គុយនិយាយគ្នាលេង លេងហ្គេមទូរស័ព្ទ នៅកន្លែងតូបលក់ផ្លែឈើនោះ រហូតដល់ម៉ោង៣ភ្លឺ ស្រាប់តែមានភាគីម្ខាងទៀតបានជិះម៉ូតូ២គ្រឿងមានគ្នា ៤នាក់ បានជិះម៉ូតូមកដល់ហើយគប់ដុំថ្មមកលើពួកខ្លួនចំនួន ២ដុំថ្ម ត្រូវម៉ូតូរបស់ឈ្មោះ [redacted] ហើយពួកខ្លួនក៏នាំគ្នាជិះម៉ូតូចំនួន ៣ គ្រឿងដេញតាមម៉ូតូរបស់ភាគីម្ខាងទៀត ចំណែកខ្លួនអង្គុយខាងក្រោយ ពួកខ្លួនជិះម៉ូតូដេញតាម រួចក៏ហូតខ្សែក្រវ៉ាត់វាយលើជនរងគ្រោះចំនួន ២ខ្សែក្រវ៉ាត់ តែមិនត្រូវជនរងគ្រោះនោះទេ រហូតដល់ចំណុចម្តុំទួលទំពូង ទើបជនរងគ្រោះផ្តួលម៉ូតូខ្លួនឯង ហើយក្រុមជនរងគ្រោះក៏បានរត់គេចខ្លួនបាត់អស់តែម្តង ឈ្មោះ [redacted]បានចុះទៅយកម៉ូតូរបស់ជនរងគ្រោះជិះតាមខ្លួនមិនដឹងថាឈ្មោះ **ហេង** ជិះម៉ូតូរបស់ជនរងគ្រោះទៅណានោះទេ ព្រោះពេលនោះខ្លួនអង្គុយនៅលើម៉ូតូ ហើយឈ្មោះ [redacted] ក៏ឌុបខ្លួនទៅផ្ទះ តែម្តង ។

ទើបថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ [redacted]បានទូរស័ព្ទប្រាប់ខ្លួនថា ឈ្មោះ [redacted]បានដោះគ្រឿងម៉ូតូរបស់ជនរងគ្រោះយកទៅលក់ ។ ខ្លួនមិនដឹងថាអ្នកណាជាអ្នកយកម៉ូតូរបស់ជនរងគ្រោះទៅផ្លូងចោលនោះទេ ។ ខ្លួនមិនបានទទួលប្រាក់ពីការលក់គ្រឿងម៉ូតូរបស់ជនរងគ្រោះនោះទេ ។ ពេលក្រុមខ្លួន ដេញតាមក្រុមរបស់ជនរងគ្រោះនោះ ក្រុមខ្លួនមិនមានអ្នកណាយកដុំថ្មទៅជាមួយនោះ ទេ ។ ខ្លួនមិនបានឃើញក្រុមខ្លួនវាយ ឬយកដុំថ្មគប់ទៅលើជនរងគ្រោះនោះទេ ។ ខ្លួនសំណូមពរសុំឲ្យតុលាការដោះលែងខ្លួនវិញ ដើម្បីខ្លួនឆាប់បានត្រឡប់ទៅផ្ទះ និងបានទៅសាលារៀន វិញ ។(ឯ.១៥/២

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស (កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ នៅសមត្ថកិច្ចនិងអយ្យការបានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ មុននឹងទៅដល់កន្លែងកើតហេតុ ខ្លួនចេញពីកោះពេជ្រចំនួន ០៥នាក់ ដោយទទួលដំណឹងថា មានគេកាប់បក្សពួករបស់ខ្លួនឈ្មោះ [redacted] ពេលនោះខ្លួន និងបក្សពួក ០៥នាក់(១-ឈ្មោះ [redacted] ២-[redacted] ៣-[redacted] ៤-[redacted] ៥-[redacted] ពេលនោះខ្លួន និងបក្សពួកបានចេញពីកោះពេជ្រនៅវេលាម៉ោងប្រហែល ០៣ និង ០០នាទី ទៀបភ្លឺថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ពេលទៅដល់កន្លែងកើតហេតុ ពួកខ្លួនបានប្រើដុំថ្មគប់ និងវាយលើក្រុមម្ខាងទៀត ។ ពេលធ្វើសកម្មភាពឈ្មោះ [redacted] និង[redacted] បានយកម៉ូតូជនរងគ្រោះទៅស៊ីគ្រឿងបានលុយ ១១០ ដុល្លារអាមេរិក ។ ក្រោយពេលបែកគ្នាឈ្មោះ [redacted]ឈ្មោះ [redacted] បានឡើងទៅខេត្តកំពង់ចាម ចំណែកខ្លួន និងអ្នកផ្សេងបានសម្ងំក្នុងផ្ទះរៀងៗ ខ្លួន ។ រហូតដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចបានឃាត់ខ្លួន តែម្តង ។ ខ្លួន និងបក្សពួកចំនួន០៨នាក់ បានធ្វើសកម្មភាពវាយលើភាគីជនរងគ្រោះយកម៉ូតូនោះមានឈ្មោះ ១-[redacted] ២-[redacted] ហៅ [redacted] ៣-[redacted] ៤-[redacted] ៥-[redacted] ៦-[redacted] ៧-[redacted] និង ៨-[redacted](ឯ.១/២២, ៣

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស (កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ នៅចៅក្រមស៊ើបសួរ បានឆ្លើយថាៈ ខ្លួនសុំបដិសេធចម្លើយនៅសមត្ថកិច្ច ដោយមូលហេតុសមត្ថកិច្ចមិនបានអានចម្លើយរបស់ខ្លួនឲ្យស្តាប់នោះទេ មិនឲ្យខ្លួនអានចម្លើយខ្លួនឯង និងសុំបដិសេធចម្លើយខ្លួនត្រង់ចំណុចថា "ខ្លួនពិតជាបានប្រព្រឹត្តអំពើវាយយកម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន" ព្រោះពេលនោះភាគីម្ខាងទៀតជាអ្នកយកដុំថ្មគប់មកលើពួកខ្លួនមុន ហើយពួកខ្លួនក៏បានជិះម៉ូតូដេញតាមវាយតបវិញ ដោយមិនមានបំណងចង់យកម៉ូតូរបស់ភាគីម្ខាងទៀតទេ ។ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៦ល្ងាច ខ្លួន និងមិត្តភក្តិចំនួន០៩ នាក់ បានជួបជុំគ្នានៅផ្សារលើលូ ស្ថិតនៅផ្លូវ៣១០ សង្កាត់ទួលស្វាយព្រៃទី២ នៅកន្លែងតូបលក់ផ្លែឈើ(លក់ផ្លែឈើ២៤ម៉ោង របស់បងមិត្តភក្តិរបស់ខ្លួន ។ មិត្តភក្តិខ្លួនមានឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ ត្រា ឈ្មោះ [redacted] និងឈ្មោះ [redacted] ចំណែកអ្នកផ្សេងចំនួន០២ នាក់ទៀត ខ្លួនមិនចាំឈ្មោះនោះទេ ។ ពេលនោះពួកខ្លួនក៏នាំគ្នាអង្គុយនិយាយគ្នាលេង និងលេងហ្គេមទូរស័ព្ទ នៅកន្លែងតូបលក់ផ្លែឈើនោះ រហូតដល់ម៉ោង ៧ល្ងាច ក៏នាំគ្នាទៅលេងកោះពេជ្រ រហូតដល់ម៉ោង០២ទៀបភ្លឺ ទើបនាំគ្នាត្រឡប់មកកន្លែងលក់ផ្លែឈើនោះវិញ ហើយក៏អង្គុយលេងនាំគ្នាញ៉ាំបាយនៅទីនោះ រហូតដល់ម៉ោង០៣ភ្លឺ ស្រាប់តែមានភាគីម្ខាងទៀតបានជិះម៉ូតូ០២ គ្រឿង មានគ្នា៤នាក់ បានជិះម៉ូតូមកដល់ហើយគប់ដុំថ្មមកលើពួកខ្លួនបណ្តាលឲ្យត្រូវខ្នងខ្លួនចំនួន១ ដុំថ្ម និងត្រូវម៉ូតូរបស់ឈ្មោះ [redacted] បណ្តាលឲ្យបែកកាបាំងមុខ ហើយពួកខ្លួនក៏នាំគ្នាជិះម៉ូតូចំនួន០៣គ្រឿង ដេញតាមម៉ូតូរបស់ភាគីម្ខាងទៀត ចំណែកខ្លួនជាអ្នកបើកម៉ូតូ មិនបានវាយគប់ដុំថ្មទៅលើភាគីម្ខាងទៀតទេ ។ ពួកខ្លួនជិះម៉ូតូដេញតាមរហូតដល់ចំណុចម្តុំទួលទំពូង ទើបជនរងគ្រោះផ្តួលម៉ូតូខ្លួនឯង ពួកខ្លួនចុះទៅដេញវាយតែខ្លួនមិនបានដឹងថាវាយត្រូវជនរងគ្រោះ ឬអត់នោះទេ ឯក្រុមជនរងគ្រោះក៏បានរត់គេចខ្លួនបាត់អស់ តែម្តង ។ បន្ទាប់មកឈ្មោះ [redacted] បានចុះទៅយកម៉ូតូរបស់ជនរងគ្រោះជិះ ពេលនោះខ្លួនក៏បានស្រែកប្រាប់ឈ្មោះ **ហេង** ថាកុំយកម៉ូតូរបស់គេអី តែឈ្មោះ [redacted] មិនស្តាប់ក៏យកម៉ូតូគេជិះចេញទៅបាត់តែម្តង បន្ទាប់មកឈ្មោះ [redacted] បាន ទូរស័ព្ទប្រាប់ពួកខ្លួនឲ្យទៅជួបជុំគ្នានៅរង្វង់មូលនាងមច្ឆា ពេលទៅដល់ខ្លួនបានប្រាប់ឈ្មោះ [redacted] ឲ្យយកម៉ូតូប្រគល់ឲ្យ

ជនរងគ្រោះវិញ តែឈ្មោះ [redacted] មិនស្តាប់ហើយថាស្អែកវាយកម៉ូតូទៅលក់ បើអ្នកណាខ្លាចមិនបាច់ចូលរួមទេ ខ្លួនក៏បានប្រាប់ឈ្មោះ [redacted] ថាកុំឲ្យពាក់ព័ន្ធដល់ខ្លួន ហើយខ្លួនក៏ត្រឡប់ទៅផ្ទះវិញ ។ ក្រោយមកឈ្មោះ [redacted] បានប្រាប់ខ្លួនថា ឈ្មោះ [redacted] និងឈ្មោះ [redacted] បានដោះគ្រឿងម៉ូតូរបស់ជនរងគ្រោះលក់ និងបានយកម៉ូតូរបស់ជនរងគ្រោះទៅទុកចោលនៅចំណុចផ្សារលើលូ នៅផ្លូវលេខ៣១០ ។ ខ្លួនមិនបានទទួលប្រាក់ពីការលក់គ្រឿងម៉ូតូរបស់ជនរងគ្រោះនោះទេ ។ ពេលក្រុមខ្លួន ដេញតាមក្រុមរបស់ជនរងគ្រោះនោះ ក្រុមខ្លួនមិនមានអ្នកណាយកដុំថ្មទៅជាមួយនោះ ទេ។ ខ្លួនមិនបានឃើញក្រុមខ្លួនវាយយកដុំថ្មគប់ទៅលើជនរងគ្រោះនោះទេ ។ ខ្លួនសំណូមពរសុំឲ្យតុលាការដោះលែងខ្លួនវិញ ដើម្បីខ្លួនបានទៅសាលារៀនវិញ ។ (ឯ.១៦/២

-របាយការណ៍សរុបលេខៈ [redacted] រ.ប.ក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យព្រហ្មទណ្ឌ មន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស កងរាជអាវុធហត្ថរាជធានីភ្នំពេញ សន្និដ្ឋានថាៈ ១-ឈ្មោះ [redacted] ហៅ [redacted] (ឃាត់ខ្លួន , ២-ឈ្មោះ [redacted] ហៅ [redacted], ៣-ឈ្មោះ [redacted] ៤-ឈ្មោះ [redacted] (គេចខ្លួន , ៥-ឈ្មោះ [redacted] (គេចខ្លួន , ៦-ឈ្មោះ [redacted] (គេចខ្លួន, ៧-ឈ្មោះ [redacted] (គេចខ្លួន , ៨-ឈ្មោះ [redacted] (គេចខ្លួន, ៩-ឈ្មោ[redacted] (គេចខ្លួន ( គេចខ្លួន ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា(ប្រើខ្សែក្រវ៉ាត់ដុំថ្មវាយយកម៉ូតូ ពីជនរងគ្រោះឈ្មោះ [redacted] ប្រាកដមែន ។(ឯ.១/៣៥

- កំណត់ហេតុទទួលវត្ថុចាប់យកលេខៈ [redacted] រ.វ.ត ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ. ៦

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ [redacted] [redacted] ដ.ព.ស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៩/២

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ [redacted] ដ.ព.ស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៩/៤

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ [redacted] ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.១០/២

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ [redacted] ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.១០/១

-ដីកាបង្គាប់ឲ្យនាំជនត្រូវចោទទៅតុលាការលេខៈ [redacted] ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។(ឯ.១១/២

-ដីកាបង្គាប់ឲ្យនាំជនត្រូវចោទទៅតុលាការលេខៈ [redacted] ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។(ឯ.១១/១

-ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខៈ [redacted] ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.១៤/៣

-លិខិតលេខៈ [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ស្តីពីសំណើសុំចាត់តាំងមេធាវី ដើម្បីការពារសិទ្ធិឲ្យជនត្រូវចោទ ។ (ឯ.១៧/២

-ពាក្យសុំបញ្ចូលកស្តុតាង ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ របស់[redacted] ។ (ឯ.១៩/៣

-លិខិតលេខៈ [redacted] ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ស្តីពីសំណើរំលឹកដីកាចាត់ឲ្យស៊ើបសួរជំនួសលេខៈ [redacted] ព្រ.ទ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ។ (ឯ.២០/២

-ពាក្យស្នើសុំម៉ូតូ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ។ (ឯ.២៣/៣

-ពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ របស់ [redacted] ។ (ឯ.២៤

-ដីកាបញ្ជូនឲ្យឆ្លើយលេខៈ [redacted] ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.២៥/២

-ដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញលេខៈ [redacted] ព្រទ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.២៦/២

-កំណត់ហេតុប្រគល់-ទទួល (៣ លេខៈ [redacted] ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.២៧

-ពាក្យសុំឲ្យកូនក្តីនៅក្រៅឃុំ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ របស់មេធាវី [redacted] ។ (ឯ.២៨

-ពាក្យសុំយកកូនមកផ្ទះ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់ [redacted] ។ (ឯ.២៩

-ពាក្យសុំយកកូនមកផ្ទះ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់ [redacted] ។ (ឯ.៣០

-ដីកាបញ្ជូនឲ្យឆ្លើយលេខៈ [redacted] ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៣១/២

-ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំលេខៈ [redacted] ដ.ព.ស ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៣២/២

-ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

**យល់ឃើញថា**[2]

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ, ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧ និងចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស (កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ និងរបាយការណ៍សរុបរបស់សមត្ថកិច្ចរួមទាំងភស្តុតាងនានាបង្ហាញថាៈ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០៣ និង ៣០ នាទីទៀបភ្លឺ ជនរងគ្រោះឈ្មោះ [redacted] និងមិត្តភក្តិ ០៣នាក់ បានជិះម៉ូតូ ០២គ្រឿង ទៅហូបបាយ ។ លុះពេលហូបបាយរួច បាននាំគ្នាជិះម៉ូតូត្រឡប់មកផ្ទះវិញនៅបុរីឡងនី(ចំការដូង ពេលចេញដំណើរមកដល់ផ្លូវ៣១០ ក្បែ សាលារៀនទួនហ្វា ស្រាប់តែមានជនត្រូវចោទមានចំនួន ០៩នាក់រួមមានៈ ១.ឈ្មោះ [redacted] ហៅ [redacted], ២.ឈ្មោះ [redacted], ៣. ឈ្មោះ [redacted] ៤-ឈ្មោះ [redacted], ៥-ឈ្មោះ [redacted] ៦-ឈ្មោះ [redacted], ៧-ឈ្មោះ [redacted], ៨-ឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូ ០៣គ្រឿង(ម៉ូតូ០២គ្រឿង ម៉ាកស្កូកពី មិនចាំស្លាកលេខ និងម៉ូតូ ០១គ្រឿងម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ មិនចាំស្លាកលេខ ហើយក្រុម ជនត្រូវចោទបានជិះម៉ូតូដេញតាមប្រើខ្សែក្រវ៉ាត់ ដុំថ្មវាយ និងគប់លើជនរងគ្រោះ និងមិត្តភក្តិ ។ បន្ទាប់មកដោយមានការភិតភ័យជនរងគ្រោះបានជិះដល់លើផ្លូវម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ក៏បានផ្តួលម៉ូតូ ០១គ្រឿងម៉ាកស្កូបពី ពណ៌ខ្មៅលាយខៀវ ស៊េរី២០២១ ស្លាកលេខ ភ្នំពេញ [redacted] របស់ខ្លួនចោល និងរត់ឲ្យគេជួយ ពេលនោះក្រុមជនត្រូវចោទក៏បានលើកម៉ូតូរបស់ជនរងគ្រោះជិះទៅបាត់ ។

-អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧, ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស

---

[2] សំអាងហេតុ សំអាងច្បាប់

អាយុ ១៦ឆ្នាំ, [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ គឺមានចេតនាក្នុងការប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ដែលមានបញ្ញត្តិតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧, ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted]ទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមហាវិថីម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-សាវតាជាតិរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ សមត្ថកិច្ចពុំទាន់បញ្ជូនរបាយការណ៍ស្រាវជ្រាវតាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ នៅឡើយ ។

-ហេតុដូចនេះ ដើម្បីពន្លឿននីតិវិធី គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧, ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ ទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ តាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា **២៤៧**, មាត្រា **៣៦៨**, មាត្រា **៣៧២** និងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

ប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖

☐ បញ្ជូនជនត្រូវចោទ៖

១.[redacted] ភេទប្រុស កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៧
២.[redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧
(ឃុំខ្លួនទៅជំនុំជម្រះ ។

ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមហាវិថីម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

☐ លើកលែងចោទប្រកាន់លើ៖

៣-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៤-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៥-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៦-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៧-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៨-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៥ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន
៩-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ (គ្មានអត្តសញ្ញាណ។(គេចខ្លួន

ពីបទៈ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមហាវិថីម៉ៅសេទុង កែងផ្លូវ៩៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃអង្គារ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣

**តំណាងអយ្យការ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ: [redacted]
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី
[redacted]

# ដីកាកោះ

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

| | | |
|---|---|---|
| អញ្ជើញឈ្មោះ | : | [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជាអ្នកបើកបរម៉ូតូ ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ [redacted] ជាជនសង្ស័យ ។ |
| ទីលំនៅសព្វថ្ងៃ | : | ភូមិអន្លង់ពោង ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។ |
| ទូរស័ព្ទលេខ | : | [redacted] |
| ឱ្យចូលទៅកាន់ | : | **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** [redacted] មានទីតាំងនៅអគារថ្មីសាលាយុត្តិធម្ម ស្ថិតនៅដីឡូត៍លេខ B តំបន់អភិវឌ្ឍន៍ OCIC ផ្លូវលោកតាក្រហមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។ |
| នៅ | : | ថ្ងៃទី ........... ខែ .................ឆ្នាំ២០២៣ វេលាម៉ោង.............................។ |
| ដើម្បី | : | សាកសួរ |
| ពីដំណើររឿង | : | លើករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ត្រង់ចំណុចផ្លូវលេខ ១០៥K ប្រសព្វផ្លូវលេខ១៦៨K សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ |

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះ ឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃ.....................................ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី.......ខែកក្កដា ឆ្នាំ២០២៣

**តំណាងអយ្យការ**

យើង.......................................ជា ....................................................................................
បានប្រគល់លិខិតអញ្ជើញនេះឱ្យឈ្មោះ..........................................................................................
..................................................................................................................
ទីលំនៅសព្វថ្ងៃផ្ទះលេខ......................ផ្លូវ......................................ភូមិ..............................
ឃុំ-សង្កាត់.............................ស្រុក-ខណ្ឌ..................................ខេត្ត-រាជធានី...................
នៅថ្ងៃទី...........ខែ................ឆ្នាំ............. ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់ឱ្យសាមីខ្លួន ហើយប្រាប់ថាឱ្យសាមីខ្លួន ប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជី នៅពេលខ្លួនចូលទៅដល់តុលាការ ឬ អយ្យការ ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**
ហត្ថលេខា ឬ ផ្តិតម្រាមដៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ ០៧០ គ.ឈ.ក.ក./១៤

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើប្រាស់បមន្តនៃដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ជាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវបមន្តនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងបមន្តនៃដីការសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃបមន្តពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័តមានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួ ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាស់ជរា។ល។ ក្នុងស្ថានភាពបែបនេះបើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមបមន្តថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១ក្នុងចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២ក្នុងចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣ក្នុងចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤ក្នុងចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្តីសម្រេច ៖

5. ចំណុចលេខ៥ក្នុងចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦ក្នុងច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិ៍ដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរាំងកុំឲ្យមានការឃុបឃិតរវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការឃុបឃិតទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីកត្តាផ្សេងៗ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីកត្តាផ្សេងៗដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណៈគ្រប់គ្រាន់ដើម្បីសម្រេចបាន គោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

តៅក្រោមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សំរាប់ប្រភេទនីមួយៗនៃរឿងក្តី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា[illegible] | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ - [illegible] |
| បទមជ្ឈិម - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ [illegible] | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈឹម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

ផ្នែកបញ្ចប់នៃទម្រង់នេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្តឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។

រដ្ឋមន្ត្រី

អង្គ-វង្សវឌ្ឍនា

ជូនភ្ជាប់ :

- គំរូទម្រង់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
  - ដើម្បីជូនជ្រាប -

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..........

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៥
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរជីកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយការុក សង្កាត់ពលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (ស្លាប់) ជាអនីតិជន ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្ដាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំនិងពិភពជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 ភ្លើងស ពណ៌ក្រហមទៅឈ្មោះ ខ្ចីយកជិះទៅធ្វើសកម្មភាពគាស់ទ្វារផ្ទះគេចូលលួចទូដែកប្រាក់ជមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្ដង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តិធម៌ដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥

# ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន

យើង .. ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៩៨៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ ដែលបើកការស៊ើបសួរពីបទ៖ សមគំនិត និងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តហិង្សា។
- បានឃើញដីកាបញ្ជូនឲ្យឆ្លើយរបស់ចៅក្រមស៊ើបសួរចុះថ្ងៃទី ....... ខែ.......... ឆ្នាំ.............
- បានឃើញមាត្រា ២០៣, ២០៥, និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី**

☐ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

☐ រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការ ត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☐ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

☐ ការពារសន្តិសុខឲ្យជនត្រូវចោទ

☐ ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

**យល់ឃើញថា ៖**

ការឃុំខ្លួនបណ្តោះអាសន្នជាមធ្យោបាយសំរាប់បញ្ចប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះ សណ្តាប់ធ្នាប់សាធារណៈ ដោយមូលហេតុៈ

☐ ភាពធ្ងន់ធ្ងរនៃបទល្មើស

☐ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស

☐ ទំហំនៃព្យសនកម្មដែលបង្កឡើងដោយបទល្មើស

**ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នលើ**

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៨ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់ភ្លាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរើសអេតចាយ នៅលីវ ឪពុកឈ្មោះ -ៗ- ម្ដាយឈ្មោះ -ស- ទោសពីមុន -គ្មាន- ជា-នីតិជន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

២០/៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុស្ដីពី
# ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

(មាត្រា ១៥០ និង មាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

មន្ទីរស៊ើបសួរ (ព)
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤០៣៩ ចុះថ្ងៃទី ១៣
ខែ តុលា ឆ្នាំ ២០១៥
លេខស៊ើបសួរ ២៦០៥
ចុះថ្ងៃទី ១៥ ខែ តុលាឆ្នាំ
២០១៥ ។

ឆ្នាំពីរពាន់ដប់ប្រាំ ខែ ធ្នូ ថ្ងៃទី មួយ វេលាម៉ោង ៨ និងសាមសិបនាទីព្រឹក

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ ៤២ ឆ្នាំ ជាតិខ្មែរ មានទីលំនៅកំណើតនៅឃុំ កំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:២៧៩ BE₀ ផ្លូវលេខ ១៨២ ភូមិទី ៨ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ ប្រធានក្រុមហ៊ុន កំរិតវប្បធម៌ ថ្នាក់ទី១២ ប្រពន្ធឈ្មោះ (រ) កូន ០៣ នាក់ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) ជានីតិជន ។

**-ជននេះ ចេះនិយាយ ចេះអាន ចេះសរសេរអក្សរខ្មែរ**

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ:២៥៩៤ អ.យ.ទ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យើងបានសួរ និងស្ដាប់ចម្លើយដូចខាងក្រោមថា៖**

ស.ឆ: ពាក្យបណ្ដឹងចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ពិតជាពាក្យបណ្ដឹងដែលខ្ញុំបាទបានធ្វើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ ដោយសមត្ថកិច្ចជាអ្នកសរសេរឲ្យ ហើយខ្ញុំបាទបានផ្ដិតមេដៃប្រាកដមែន ។

ស.ឆ: ខ្ញុំបាទសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ នៅម៉ោងប្រហែល ៤ ទាបភ្លឺ សមត្ថកិច្ចប៉ុស្តិ៍នគរបាល បានទូរស័ព្ទមកសួរខ្ញុំបាទបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្ញុំថាតើខ្ញុំបាទពិតជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុននោះមែនឬអត់ ? ដោយគាត់បញ្ជាក់ប្រាប់ថា ឃើញក្រុមហ៊ុនរបស់ខ្ញុំបានត្រូវបើកទ្វារ និងបែកទ្វារកញ្ចក់ និង ឲ្យខ្ញុំបាទទៅពិនិត្យមើល ភ្លាមនោះ ខ្ញុំបាទក៏បានទៅមើលភ្លាមដែរ នឹងបានឃើញដូចអ្វីដែលសមត្ថកិច្ចបានប្រាប់ខ្ញុំបាទមែន ។ បន្ទាប់ពីបានពិនិត្យមើលឃើញទូរដែករបស់ខ្ញុំមួយត្រូវបានបាត់ក្នុងនោះ (មានប្រាក់ប្រហែលចំនួន ៥០.០០០ $ (ប្រាំម៉ឺនដុល្លារអាមេរិក) និង លុយខ្មែរចំនួន២.០០០.០០០ ៛,០០ (ពីរលានរៀល) ព្រមទាំងឯកសារមួយចំនួន ដូចជា លិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លីមួយកន្លែង និង សៀវភៅធនាគារចំនួន ៣ ក្បាល, ឯកសារពាក់ព័ន្ធនិងក្រុមហ៊ុនរបស់ខ្ញុំបាទ ហើយរបស់របរផ្សេងទៀតត្រូវរើកកាយ។

ស.ឆ: ក្នុងខណៈនោះ ជនល្មើសពុំទាន់ត្រូវបានចាប់ខ្លួនបានទេ ក្រោយមកទើបសមត្ថកិច្ចកំណត់មុខសញ្ញា ដោយផ្អែកតាមរយៈកាមេរ៉ាសុវត្ថិភាពដែលបញ្ជាក់ពីមុខសញ្ញា និង តាមការពិនិត្យទៅលើក្រយៅដៃ ទើបឈានដល់ការឃាត់ខ្លួនជនល្មើសបាន ។

ស.ឆ: ក្នុងរឿងនេះ ខ្ញុំបាទប្តឹងសុំទាមទារសំណងជាប្រាក់ដែលត្រូវបានបាត់បង់ ចំនួន **៥០.០០០ $** ( ប្រាំម៉ឺនដុល្លារអាមេរិក ) និង លុយខ្មែរចំនួន **២.០០០.០០០ ៛,០០** ( ពីរលានរៀល ) និងសម្ភារៈដែលបានបាត់បង់ជាឯកសារ និងពុំទាមទារសំណងជម្ងឺចិត្តអ្វីពីជនល្មើសទេ តែសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ចុះ ។

យើងបានឲ្យដើមបណ្តឹងអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយដើមបណ្តឹងមិនបានបដិសេធត្រង់ចំណុចណាទេ និង បានចុះហត្ថលេខាជាមួយយើង និង ក្រឡាបញ្ជី ។

| | | |
|---|---|---|
| **ដើមបណ្តឹងរដ្ឋប្បវេណី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
លេខ 358 (ក)ដឃដ

2001 16 34/3

# ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៣ តក្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

## យល់ឃើញថា

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្តាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ។

## ហេតុដូច្នេះសម្រេច

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម២) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ភេទប្រុស អាយុ ១៤ឆ្នាំ រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

បានទទួលដំណឹង
រាជធានីភ្នំពេញថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦
ឧ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ១៤០ ជជ

## ដីកាលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ    ភេទប្រុស ,ឈ្មោះ    ភេទប្រុស និងឈ្មោះ    ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ុហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ...៦៨... អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី ...១៦... ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤៧ ដ.ជ

## ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នលេខ៦៩៩,៦៩១,៦៩០(ក)ដយដ ចុះថ្ងៃទី.....១៤..... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្លលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្លលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៨.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្ដីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

បានទទួលដំណឹង
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦
ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៤០៣៩
ចុះថ្ងៃទី១៣/១០/២០១៥
ជំនុំជំរះលេខ: ១៥៧
ចុះថ្ងៃទី២២/០១/២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ: ១៤១ ក្រ៨ ·ជ·
ចុះថ្ងៃទី២២/០៤/២០១៦

### តាមនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៩.៣០នាទី ព្រឹកដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក                ប្រធានក្រុមប្រឹក្សា
លោក                ចៅក្រមប្រឹក្សា
លោក                ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក                ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី                ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ មានជនជាប់ចោទ:

១/ឈ្មោះ          ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរដើររើសអេតចាយ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក សង្កាត់វាស្សរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ     (ស) ម្តាយឈ្មោះ (រ)នៅលីវ ជាអនីតិជន ។

-ឃាត់ខ្លួននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៩ ត.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

២/ឈ្មោះ          ហៅ          ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ          (ស) ម្តាយឈ្មោះ          (រ) ប្រពន្ធឈ្មោះ          (រ) ជានីតិជន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ៣៥២៦ តព ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣/ឈ្មោះ          ហៅ          ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរដើររើសអេតចាយទីកន្លែងកំណើតស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក

សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ជាអនីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៤ កព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤/ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស)ម្តាយឈ្មោះ (រ)ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន(ក្រៅឃុំ) ។

ដោយមានកញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរជាប្រធានក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍និងពាណិជ្ជ ទីលំនៅកំណើតឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧៩BEo ផ្លូវ១៨២ ភូមិ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២០៩ ដ.ដ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

<u>អង្គហេតុដែលត្រូវបានចោទប្រកាន់និងបញ្ជូនមកជំនុំជម្រះ</u>

កាលពី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣.១៥នាទីទាបភ្លឺជនជាប់ចោទឈ្មោះ ,ឈ្មោះ ហៅ ,ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 PLUS ពណ៌ក្រហមគ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ ដោយមាន សណ្តោងរ៉ឺម៉កដែលជាកម្មសិទ្ធិរបស់ឈ្មោះ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ិនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសឆ្កឹះសោទ្វាខាងមុខចំណែកជនជាប់ចោទឈ្មោះ បានឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួន១ ដែលក្នុងនេះមានប្រាក់ចំនួន

ប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និង ឯកសារប្លង់ដីព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួន១ បន្ទាប់មកជនជាប់ចោទបានគេចខ្លួនទៅផ្ទះរបស់ឈ្មោះ ហើយបានយកប្រាក់ទាំងនេះចែកជាចំណែក ដោយឈ្មោះ ទទួលបានប្រាក់ចំនួន១លានរៀល បន្ទាប់មកជនជាប់ចោទឈ្មោះ បានយកប្រាក់ចំនួន៤,០០០$ផ្ញើទុកនៅនឹងឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទរបស់ឈ្មោះ ។ ចំណែកជនជាប់ចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវហើយឃាត់ខ្លួនជនជាប់ចោទបានចំនួន២នាក់គឺឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតបានវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទី ខ្ញុំពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយគ្រឿងម៉ាកសេ១០០កង់ផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកកកន្ទុយរ៉ឺម៉កបានដឹកខ្ញុំនិងបក្ខពួកផ្សេងទៀតឈ្មោះ , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលពួកខ្ញុំធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្ញុំក៏បានឈប់ម៉ូតូហើយខ្ញុំក៏បានយកទួណឺវីសមកឆ្កឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសារផ្សេងទៀត រួចហើយបានចែកលុយគ្នាដោយខ្ញុំទទួលបានប្រាំពាន់ដុល្លារអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្ញុំបានយកលុយចំនួន៤ពាន់ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានពួកខ្ញុំបានយកទៅចាយវាយនិងចែកអ្នកជិតខាង នៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទីរសៀលខ្ញុំកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ខ្ញុំពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាកដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្ញុំឲ្យយកទៅគេនៅម្តុំច្បារអំពៅ ពេលនោះខ្ញុំក៏បានជិះម៉ូតូម៉ាកសង់សេ១០០ កង់ផ្លើសពណ៌ក្រហមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្ញុំជិះរួចខ្ញុំក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញមូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្ញុំគឺម៉ូតូរបស់ខ្ញុំមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ឲ្យខ្ញុំមកយកម៉ូតូ និងបានឲ្យលុយមកខ្ញុំចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្ញុំបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: ខ្ញុំពិតជាបានចូលរួមកាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្ញុំលួចបានទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្ញុំ ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្ញុំបានចំនួន១០,០០០$ លុះសល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បាររអំពៅ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅពេលសវនាការថា: កាលពី ថ្ងៃទី០៨ខែតុលា ឆ្នាំ២០១៥ ខ្ញុំបានចេញពីក្រុមហ៊ុនរបស់ខ្ញុំមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេល ខ្ញុំកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ខ្ញុំថា ក្រុមហ៊ុនរបស់ខ្ញុំត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្ញុំក៏បាននមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ នៅក្នុងរឿងនេះខ្ញុំសុំទាមទារប្រាក់ដែលបានបាត់បង់ទៅសរុបចំនួន ៥០,០០០$ លុយខ្មែរចំនួន ២,០០០,០០០រៀល ព្រមទាំងឯកសារផ្សេងៗទៀត ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ . នៅពេលសវនាថា : កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្ញុំបាន ចេញពីក្រុមហ៊ុនត្រលប់ទៅផ្ទះសម្រាក ហើយខ្ញុំបានចាក់សោរទ្វាត្រឹមត្រូវលុះទាមភ្លឺថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្ញុំបានទូរសព្ទ័មកប្រាប់ខ្ញុំថា នៅក្រុមហ៊ុនមានចោរ ចូលគាស់ទ្វា ពេលនោះខ្ញុំក៏ប្រញាប់មកក្រុមហ៊ុន ទើបដឹងថាចោរបានលួចយកទូរដែក១នៅ ក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន ។

-តំណាងយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់ឃើញថា ជនជាប់ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជដោយលួចបានទូរដែកចំនួន១ ហើយនៅក្នុងទូរដែកនេះមានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ រួចហើយពួកខ្លួនក៏បានយកលុយទៅចែកគ្នាអស់ ចំណែកឯកសារផ្សេងៗពួកគេបានយកទៅបោះចោលអស់ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុក នៅដដែល ដោយជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ

ពីបទ លួចមានស្ថានទម្ងន់ទោស សមគំនិតក្នុងអំពើលួច ដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩និងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមនរាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ . បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិថា : កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជកម្មពិតប្រាកដមែនដូច្នេះសុំឲ្យលោកប្រធានក្រុមប្រឹក្សា មេត្តាជួយសម្រាលទោសឲ្យកូនក្តីខ្ញុំដោយអនុគ្រោះចំណែកខ្ញុំឈ្មោះ ខ្លួនមិនបានដឹងអីទេសូមឲ្យលោកប្រធានក្រុមហ៊ុន មេត្តាលើកលែងឲ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ។

*-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ*

*-ក្រោយពីបានពិនិត្យគ្រឿងតាង និងឯកសារនានាក្នុងសំណុំរឿង*

*-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ*

*-ក្រោយពីក្រុមប្រឹក្សាបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

<u>**សាលាដំបូងរាជធានីភ្នំពេញ**</u>

<u>**យល់ឃើញថា**</u>

១/តាមរបាយការណ៍សំយោគលេខ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ផ្អែកតាមរបាយការណ៍នគរបាលប៉ុស្តិ៍ តាមពាក្យបណ្តឹងរបស់ជនរងគ្រោះ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឃើញថាឈ្មោះ និងឈ្មោះ

ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (គាស់សោទ្វាក្រុមហ៊ុនលួចទូដែក) កាលពីវេលាម៉ោង៣,១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃ ទី៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនទេសចរណ៍ និងពាណិជ្ជដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BE០ ផ្លូវ៣៤៨ ក្រុម១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែនចំណែកជនជាប់ចោទឈ្មោះ ពិតជាបានសមគំនិត ផ្តល់មធ្យោបាយធ្វើសកម្មភាព និងទទួលផលចោលកម្មក្នុងករណីនេះប្រាកដមែនរីឯជនជាប់ឈ្មោះ ដែលជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្មក្នុងករណីខាងលើនេះដែរ ។

២-តាមចម្លើរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយ គ្រឿងម៉ាកសេ១០០ក្បូរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ') មកតកន្ទុយរ៉ឺម៉កខ្លួនបានដឹកបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលខ្លួនធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូហើយក៏បានយកទូឡឺវីសមកឆ្កឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុង ក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅ ផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាខ្លួនទទួលបានប្រាំពាន់ដុល្លាអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្លួនយកលុយចំនួន៤ពាន់

ដុល្លារអាមេរិក ទៅផ្ញើនឹងឈ្មោះ នៅសល់ប៉ុន្មានខ្លួនបានយកទៅចាយវាយ និងចែកអ្នកជិតខាងនៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣,០០នាទីរសៀលពេលដែលខ្លួនកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមក ឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

៣/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាក់ដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ

បានឲ្យទូរសព្ទមកខ្លួនឲ្យយកទៅគេនៅមុំច្បារអំពៅ ពេលនោះក៏បានជិះម៉ូតូម៉ាក សងសេ១០០ ក្បាលផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូខ្លួនជិះរួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរគឺម៉ូតូរបស់ខ្លួនមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ខ្លួនថាឲ្យមកយកម៉ូតូ និងបានឲ្យលុយខ្លួនចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្លួនក៏បានជិះម៉ូតូមកអង្គុយ លេងជាមួយឈ្មោះ ... និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនជាមួយឈ្មោះ នាំមកតែម្តង ចំណែកឈ្មោះ បាន រត់គេចខ្លួនបាត់ ។

៤/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា៖ ខ្លួនពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ , ឈ្មោះ ...,ឈ្មោះ .. ហៅ .. ។ ពេលនោះពួកខ្លួនលួចបានទូដែក១ យកទៅបើកនៅផ្ទះខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្លួនបានចំនួន ១០,០០០$ លុះ សល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ ។

៥/តាមចម្លើយបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ្លើយថា៖ កាលពី ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ខ្លួនបានចេញពីក្រុមហ៊ុនដែលមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទប្រាប់ថា ក្រុមហ៊ុនរបស់ខ្លួនត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្លួនក៏បានមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ ។

៦/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ,ឈ្មោះ . , ឈ្មោះ

បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់បណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីនិងភស្តុ តាងនានានៅក្នុងសំណុំរឿងថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចគាស់ទ្វាក្រុមហ៊ុនស៊ី ហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែន ។

៧/ជនជាប់ចោទមានស្មារតីល្អនៅពេលប្រព្រឹត្តបទល្មើស អំពើប្រព្រឹត្តរបស់ជនជាប់ជាប់ចោទឈ្មោះ , ឈ្មោះ " . ពី , ឈ្មោះ . . , និងឈ្មោះ .

បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គមយ៉ាង

ចូន់ចូរដែលដែលធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងផ្ទុយទៅនឹងច្បាប់កំណត់ ។

៨/ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជាអនីតិជនតុលាការគប្បីពិចារណាពីស្ថានសម្រាល ។

៩/តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១០/មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ , ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

១១/វត្ថុចាប់យកមាន:

១១.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខៗម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែក្ប) និង អង្គចងចាំចំនួន១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

១១.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដាក់គ្រឿងញៀនចំនួន១តុលាការគប្បីសម្រេចរឹបអូស ។

១២/ដើមបណ្តឹងសុំទាមទារសំណង ជាប្រាក់ដែលបានបាត់បង់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ,លុយខ្មែរចំនួន២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈដែល បានបាត់បង់ជាឯកសារ តុលាការគប្បីសម្រេចតាមច្បាប់ ។

<u>ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ</u>

**ចិនិច្ឆ័យសេចក្តី**

១/ផ្តន្ទាទោស:

១.១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈ ០២ឆ្នាំ (ពីរឆ្នាំ) និងឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៤ឆ្នាំ (បួនឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១សង្កាត់ ទួលស្វាយព្រៃ

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.២/ផ្តន្ទាទោសលើឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.៣/ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាងគារកំណត់គយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុចាប់យកមាន:

២.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ។ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្បូ) និង អង្គចងចាំចំនួន១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

២.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងគោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដាក់គ្រឿងញៀនចំនួន១រឹបអូស ។

៣/បង្គាប់ឲ្យឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណងដែលបានបាត់បង់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) , លុយខ្មែរចំនួន ២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈ ដែល បានបាត់បង់ជាឯកសារ ទាមទារលើសពីនេះបដិសេធន៍ចោល ។

៤/បង្គាប់ឲ្យចេញដីកាចាប់និងឃុំខ្លួនឈ្មោះ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ខែមេសា ឆ្នាំ ២០១៦ចំពោះមុខជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីទុកសិទ្ធិប្តឹងទាស់ និងបើផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី២២ខែមេសា ឆ្នាំ២០១៦
ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាមប្រជាពលរដ្ឋខ្មែរ
តុលាការកំពូល

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៨១
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩
សាលដីកា
លេខ: ២៦៧
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម | ជាប្រធាន |
| ២-លោកស្រី | ជាចៅក្រម |
| ៣-លោក | ជាចៅក្រម |
| ៤-លោក | ជាចៅក្រម |
| ៥-លោក | ជាចៅក្រម |

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ របស់តុលាការកំពូល។

<u>ពីបទ</u>: នាំពង្រត់ និងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ឃុំកំពង់ស្វាយ ស្រុកសិរីសៅភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧។ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីបង្ក្រាប់អំពើនាំពង្រត់ លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទឈ្មោះ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស <u>អាយុ១៦ឆ្នាំ</u> ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ទីលំនៅសព្វថ្ងៃនៅភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបររកស៊ីគ្មាន ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ទោសពីមុនគ្មាន។

-មានមេធាវីលោក និង

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ "ម្ចាស់បណ្ដឹងសាទុក្ខ" ភេទស្រី អាយុ៤២ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរមេផ្ទះ ទូរស័ព្ទលេខ០១២ ៧០១ ៧១៨ (ត្រូវជាម្ដាយជនរងគ្រោះ)។

-ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ១៨ឆ្នាំ មុខរបរសិស្ស។

-តាមពាក្យបណ្ដឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ ថាកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង១៣:០០នាទី នាងខ្ញុំទើបតែមកពីផ្សារ ចូលផ្ទះភ្លាមក៏លឺស្នូរខ្ទរជញ្ជាំងក្ដារកន្លែងបន្ទប់កូនស្រីរបស់ខ្លួនឈ្មោះ អាយុ១៨ឆ្នាំ លឺដូច្នេះខ្លួនក៏ចូលទៅមើលក្នុងបន្ទប់កូនស្រីរបស់ខ្លួនៗឃើញស្នាមជើងឡើងលើពិដាន ខ្លួនឡើងតាមមើលក៏ឃើញឈ្មោះ ភេទប្រុស <u>អាយុ១៦ឆ្នាំ</u> នៅពួនលើពិដានផ្ទះក្នុងសភាពអាក្រាត ខ្លួនក៏បណ្ដេញចេញពីផ្ទះ។ ក្រោយបន្តិចមកខ្លួនទៅផ្សារលុះម៉ោង៣:០០នាទីរសៀល ខ្លួនក៏ត្រលប់មកផ្ទះវិញ ក៏ស្រាប់តែបាត់កូនស្រីនាងខ្ញុំរហូតដល់សព្វថ្ងៃនេះ។

-បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេច៖

១-លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩១ ជាតិខ្មែរ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរនៅផ្ទះ នៅលីវ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" ទោសពីមុនគ្មាន ពីបទរំលោភសេពសន្ថវៈ និងនាំព្រាត់មនុស្ស ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ តាមមាត្រា៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើនាំពង្រត់លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។

២-ឲ្យឈ្មោះខាងលើមានសេរីភាពឡើងវិញ ប្រសិនបើឈ្មោះនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសអ្វីផ្សេងទៀត។

-បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ គ្រប់ចំនុចនៃសេចក្ដីសំរេចទាំងមូល។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈគួរតប្បីឲ្យរួចពីការចោទប្រកាន់ និងសុំឲ្យតម្កល់ដីកាលើកលែងចោទប្រកាន់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដាឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសនាពេលសវនាការអសាធារណៈនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ប្តឹងជំទាស់ទាំងស្រុងនឹងសាលដីកាព្រហ្មទណ្ឌលេខ៩៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍គ្រប់ចំណុចនៃសេចក្តីសម្រេចខាងមុខ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

-ទទួលបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តា ពិនិត្យនិងសំរេចតាមច្បាប់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ការពារជនជាប់ចោទឈ្មោះ នាពេលសវនាការថា៖កូនក្តីខ្ញុំជាមួយ ពិតជាស្រលាញ់គ្នាពិតប្រាកដគ្មានការរំលោភទេ ព្រោះ បានឆ្លើយថានាងខ្ញុំ និង បានស្រលាញ់គ្នាយូរហើយ កូនក្តីខ្ញុំជាមួយនាង បានស្រលាញ់គ្នាតាំងពីឆ្នាំ២០០៦ តែដោយសារកាបង្គាប់លុយក្នុងការរៀបកា ខាងស្រីបានឲ្យកូនក្តីខ្ញុំបង់លុយក្នុងការរៀបការច្រើនពេក តែកូនក្តីខ្ញុំមានតែ៥០០$ ទើបបានខាង ស្រីប្តឹងចោទថាកូនក្តីខ្ញុំចាប់រំលោភ។

សំណូមពរ: តម្កល់សាលដីការបស់សាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>តុលាការកំពូល</u>**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៧២ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា តាមកំណត់ហេតុសួរចម្លើយចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ របស់តុលាការខេត្តបន្ទាយមានជ័យ ក៏ដូចជានាពេលសវនាការនៅតុលាការអង្គសេចក្តីផងដែរ ឈ្មោះ និងឈ្មោះ បានឆ្លើយប្រាប់តុលាការថាពួកខ្លួនទាំងពីរនាក់បានស្រលាញ់គ្នាពិតប្រាកដមែនដោយគ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងអ្វីឡើយ ហើយឪពុកម្តាយអ្នកទាំងពីរក៏បានដឹងឮថាអ្នកទាំងពីរបានស្រលាញ់គ្នាដែរ មូលហេតុដែរឈ្មោះ និងឈ្មោះ ព្រមព្រៀងគ្នារត់ចេញពីផ្ទះនោះដោយសារតែ ឪពុកម្តាយមិនព្រមរៀបការឲ្យពួកគេ ហើយសព្វថ្ងៃនេះអ្នកទាំងពីរកំពុងរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៀតផង។ ដូច្នេះឃើញថាពុំមានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទពីបទ: នាំពង្រត់ និងរំលោភសេពសន្ថវៈដូចពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ នោះទេ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៥-ស- ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ
។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៥-ស- ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ និងប្រកាសសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២។

ប្រធាន ចៅក្រម ចៅក្រម ចៅក្រម ចៅក្រម ក្រឡាបញ្ជី ,

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១២
ក្រឡាបញ្ជី

បានឃើញ
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១២
ជ.ប្រធានតុលាការកំពូល
អនុប្រធាន